សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការឿង

Issue 166 05th-Dec 19.th, 2014

Free

១-ដំណើរពីអាមេរិកទៅអាស៊ី............................០៤
២-ត្រូវនឹងខុស............................................០៥
៣-សមត្ថកិច្ច : ឧកញ៉ា ថោង សារ៉ាត់ ជាមេក្លោង..០៧
៤-អាចិកំចាំងធ្វើឱ្យស្បែកស្អាត........................១០
៥-មាតាបិតាគួរបង្រៀនកូនឲ្យសន្សំលុយ..................១២
៦-បញ្ហានៃការឈានទៅរកភាពគ្មានផ្ទះ.................១២
៧-រមណីយដ្ឋានទឹកធ្លាក់នៅខេត្តកំពង់ចាម...............១៤
៨-ទស្សនៈមិត្តអ្នកអាន..................................១៧

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

### ពាណិជ្ជកម្មចុងឆ្នាំសាកល


ពិន សំខុន

**ដោយ : ពិន សំខុន**

ដូចរៀងរាល់ឆ្នាំចុងខែវិច្ឆិកា នឹងខែធ្នូ ជាឱកាសដែលពាណិជ្ជករតូចធំនាំគ្នាបញ្ចប់ឆ្នាំដោយបង្កើនប្រាក់ចំណូលបានក្រាស់ក្រែល រីឯអតិថិជនក៏រីករាយនឹងចាយលុយណាស់ដែរ ក្នុងអំឡុងពេលដដែលនេះ។ អ្នកទិញដកលុយចេញពីហោប៉ៅជាថ្នូរបស់ល្អៗឡាយឡុងរហូតដល់ពាក់កណ្ដាលថ្ងៃ រីឯអ្នកលក់ដាក់លុយចូលថង់ឡើងប៉ោង បាតវ៉ាន់លក់បង្ហើយចេញពីឃ្លាំងអស់រលីងមុននឹងដាក់ឱ្យស្តុកឱ្យឆ្នាំថ្មីបញ្ចូលទៅវិញ។ យ៉ាងនេះ លុយមានចរន្តបានបូរពី **តទៅទំព័រទី ១១**

## បញ្ហាអន្តោប្រវេសន៍នៅសហរដ្ឋអាមេរិក

**ដកស្រង់ពីវ៉ាស៊ីនតុន ដោយ : ថាច់ វណ្ណា**

ពេលថ្មីៗនេះលោកប្រធានាធិបតីបារ៉ាក់ អូបាម៉ា បានធ្វើសេចក្ដីសម្រេចចិត្តជាឯកតោភាគីធ្វើការផ្អាកនិរទេសជនអន្តោប្រវេសន៍ខុសច្បាប់ជិត៥លាននាក់ចេញពីសហរដ្ឋអាមេរិក ។ ដោយមិនគោរពទៅតាមសមាជសភានៃគណបក្សសាធារណរដ្ឋ និងប្រឈមមុខទៅនឹងការចោទប្រកាន់ថា : ប្រមាថដល់ច្បាប់រដ្ឋធម្មនុញ្ញ ពីព្រោះលោក បាម៉ា ធ្វើផ្ទុយទៅនឹងសេចក្ដីថ្លែងការណ៍របស់ខ្លួនដែលបានសម្ដែងថា : លោកនឹងមិនប្រើអំណាចរបស់ខ្លួនដើម្បីផ្លាស់ប្ដូរទាំងស្រុងក្នុងទីសមាជសភានោះឡើយ ។

**តទៅទំព័រទី ០៨**




## ទៅលេងគ្រួសារនៅស្រុកបាយឆៅនាកម្ពុជាក្រោម (ភាគ២)

**ដោយ : ពិន សំខុន**

នៅបាយឆៅក្រុមគ្រួសារសុបិន ថ្វីត្បិតតែក្រីក្រតែទទួលយើងបានល្អណាស់បងប្អូនញាតិមិត្តទោះជានៅជិត ឬឆ្ងាយបានដំណឹងថា ប្អូនស្រីសុបិនដែលបានចេញទៅអាមេរិកកាលពី១៥ឆ្នាំមុនឥឡូវគេមកលេងស្រុកជាមួយគ្រួសារនឹងកូនប្រុសគេទាំងអស់ ហើយក៏នាំគ្នាមកលេងមិនដាច់។

បាយឆៅជាជនបទនៃខេត្តភាគខាងត្បូងវៀតណាមមិនមានផ្ទះធំខ្ពស់ទេ ផ្ទះស្លឹកជាច្រើន ដែលបានខ្លាយជាផ្ទះថ្មខ្លះទៅហើយក្ដី ក៏នៅរក្សាទំហំនៃផ្ទះដើមទាំងអស់នៅឡើយ តែគេបានទីលំនៅនឹងទីធ្លាស្រស់ស្អាត ហើយនឹងមានអនាម័យជាងមុន។ នៅជុំវិញផ្ទះសុទ្ធសឹងមានដំណាំបន្លែបង្កានឹងដើមមានផ្លែ ដូចជាល្ហុង ចេក ស្វាយ ខ្នោមិនខ្វះចន្លស់ ។ បងប្រុសធំ សុបិន ឈ្មោះ លាង បានឱ្យដឹងថា "ខ្លួនមានដី១០កុងឪពុកនៅសហរដ្ឋអាមេរិកជួយឱ្យលុយ៤ពាន់ធ្វើផ្ទះថ្មបានមួយលើដី១កុង **តទៅទំព័រទី ០២**



សុបិននាំគ្រួសារទៅលេងនៅសួនឧទ្យានបឹងឈូក នៅព្រៃនគរ


ថតនៅមុខស្រះប្រវត្តិសាស្ត្រឈ្មោះស្រះគូ នៅខេត្តព្រះត្រពាំង

ការិយាល័យ មេធាវី
ថំមាស ស្ទាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

## តមកពីទំព័រទី ០១ ទៅលេងគ្រួសារនៅស្រុកបាយឆៅ...

សម្រាប់រស់នៅជាមួយប្រពន្ធនឹងកូន៣នាក់នឹងសង់ក្រោលចិញ្ចឹមគោ៣សម្រាប់លក់ដី៨កុងទៀតទុកធ្វើស្រែ៣រដូវ១កុងទៀត ទុកដាំស្មៅចិញ្ចឹមគោរបៀបនេះគាត់អាចមានស្រូវ១៥០បាវក្នុងមួយរដូវនឹងលក់គោ៣ក្នុងមួយឆ្នាំសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារបានតែគាត់មិនអាចផ្គត់ផ្គង់ឱ្យកូនទៅរៀនវែងឆ្ងាយបានទេ"។

ពេលចេញពីរៀនសិស្សក្នុងសំពត់ ឬខោខ្មៅអាវសមានកន្សែងក្រហមចងកនិស្សិតនារីអាវផាយសស្តើងជិះកង់ជាជួរត្រឡប់ទៅផ្ទះយ៉ាងមានសណ្តាប់ធ្នាប់សូបិននិយាយថា "កាលពីនៅក្មេងចង់បានពាក់អាវផាយនោះណាស់ ពីព្រោះជាមោទនភាពនៃនិស្សិតស្ត្រីវៀតណាមដែលផ្តើមពេញវ័យ"។ សាលារៀនលំអដោយទង់ក្រហមផ្កាយលឿងដែលនៅតាមផ្លូវចាក់កៅស៊ូនៅអមដោយវត្តខ្មែរធំៗដល់ទៅ៣ គឺជាសាលាដែលសូបិនធ្លាប់រៀននៅទីនោះ ធ្លាប់ដើរកាត់ផ្ទះ



សូបិន រីករាយពេលបានជួបម្តាយ បន្ទាប់ពីបែកគ្នា១៥ឆ្នាំ

មាមីងតែមិនហានចូលសុំអីហូបទេ ពេលឃ្លានម្តងៗជាភូមិឋានប្រកបដោយអនុស្សាវរីយនាយុវភាពរបស់សូបិន ។ ខណៈនេះកូនច្បងៗរបស់បងប្រុសសូបិនអាយុប្រមាណ១៥ឆ្នាំ បានបោះបង់សាលាស្ទើរអស់ទៅហើយ ដើម្បីសម្រាលបន្ទុកម្តាយឪពុកដែលសូបិនអាក់អន់ចិត្តជាទីបំផុត ដោយមិនបានឃើញស្ថានភាពក្មួយៗពីមុនពេលទៅដល់ទីកន្លែង។ ដើម្បីស្តារកំហុស សូបិន នាំក្មួយ មាមីង ដើរកំសាន្តទីរមនីយដ្ឋានឆ្ងាយៗដែលអ្នកទាំងនោះមិនដែលបានទៅដល់ឱ្យឃើញកន្លែងគេរកស៊ីធំៗ នាំទៅភ្លក់ចំណីអាហារដែលមិនដែលហ៊ានលូកបង្រៀនពីការខំស្វែងរកលុយដោយរៀនសូត្រចិញ្ចឹមសត្វដោយមានគម្រោងច្បាស់លាស់ធ្វើស្រែចំការឱ្យមានប្រាក់ចំណេញតែ សូបិន មានពេលតិចពេកសម្រាប់ធ្វើចំណេះក្លាយទៅជាទម្លាប់បានត្រឹមតែចងចាំនូវការរីករាយជួបជុំគ្រួសារតែប៉ុណ្ណោះ។



ទីប្រជុំជនរួមខេត្ត គឺត្រាវិញមានមនុស្សធ្វើពាណិជ្ជកម្មច្រើន ថ្វីត្បិតតែនៅជុំវិញ មានខ្មែរច្រើន តែក្រុងពាណិជ្ជកម្មសម្បូរវៀតណាមនឹងចិនជាធម្មតាតែខ្មែរក៏មានខ្មែរច្រើនណាស់ដែរខិតខំជ្រៀតចូលវិស័យសេដ្ឋកិច្ចនេះ។ មានផ្សារលក់ទំនិញចំរុះផ្ទាល់ដីមានបន្លែបង្កា ត្រី សាច់គ្រឿងទេស ដូចស្រុកខ្មែរដែរ មានផ្សារទំនើបតែឥវ៉ាន់ប្រើប្រាស់ម្ហូបចំណីមិនមានតម្លៃខ្ពស់ដូចស្រុកខ្មែរទេ បើនៅជនបទរឹតតែថោកថែមទៀត អ្នកមាននឹងអ្នកក្រមានលទ្ធភាពទិញដោយសុវត្ថភាពគ្រប់គ្រាន់ដូចគ្នា។ មធ្យោបាយដឹកជញ្ជូន គឺមានកង់នឹងម៉ូតូច្រើនជាងគេបង្អាប់មកមានរថយន្តតូចនឹងធំតែពុំមានឃើញ រឺម៉ក ឬសីក្លូដឹកមនុស្សទេ។ ធាតុអាកាសនាខែវិច្ឆិកានេះ មានកំដៅស្ទុះស្អាប់សម្រាប់យើងជាអ្នកទៅពីស្រុកត្រជាក់នៅឡើយ រីឯអ្នកនៅឯនាយឃើញ២៧អង្សារថា ត្រជាក់ល្មមសម្រាប់ពួកគេដែលនាំគ្នាអង្គុយសំដិល នាទៀមកាហ្វេ មានអ្នកអានកាសែតមួយៗដែរ។

តទៅទំព័រទី ១៣






| Washington SAVINGS BANK We give you more | | Big Banks |
|---|---|---|
| ATMs | 60,000 Nationwide free ATMs | Much Less! |
| Free Checking | YES! | Are you kidding? |
| Online Banking | Everything the 'Big Banks' have: Online banking, Bill payment, mobile banking, mobile deposit | We'll give them this one, they have it too |
| Free Designer Debit Card | YES, OVER 80 DESIGNS! | They are not that creative |
| Unlimited Debit Card Cash Rewards | YES! Anytime, Anywhere | No |
| Customer Service | Friendly local people who really want to help solve problems | One word "Voicemail" |
| Lending | Local decisions, by local people who sincerely want to work with you. Your place or ours, day, evening or weekend | See above |
| Bank Headquarters | Lowell, MA - your money and loan payments stay in your community | Canada, Spain Scotland, North Carolina |

"I switched from a large bank several years ago and have never regretted it. This is a small town bank with large bank benefits and far superior service than you get at the larger banks." - Joe S."

"I recently switched from Bank of America and love it here. Should have done it sooner!" – Kelly P.



**PLUS RECEIVE A FREE**

**kindle fire®**

- Monthly Direct Deposit of at least $1,000
- At least one monthly automatic payment
- An active debit card

Washington SAVINGS BANK
We give you more

washingtonsavings.com

**978-458-7999**

Member FDIC/ Member DIF / Equal Housing Lender

See reverse side for terms and conditions

# ដំណើរពីអាមេរិកទៅអាស៊ី

**តពីលេខមុន**

សំនួរនេះថា ស្រីចិននោះគេនិយាយជាមួយប៉ាជាភាសាអាមេរិកាំង! គួរឱ្យចង់សើចកូនវាឱទ្ធានថាអូ! រួចក៏ដើរចេញទៅ។


ផ្សារបណ្តែតទឹកនៅថៃ

នឹកដល់រឿងចិនដែលធ្លាប់លូកដៃដំក្រខ្វក់មកជួយមនុស្សមួយក្តាប់តូចនៅស្រុកខ្មែរថា ហុងកុងមានអធិបតេយ្យក្នុងការគ្រប់គ្រងតាមគំរូអង់គ្លេសដដែលចំនួន៥០ឆ្នាំទៀត បន្ទាប់ពីបេយឹងកាន់កាប់ដីវិញតែបេយឹងចាប់ប្តើមដាក់ដង្កៀបលើហុងកុងដែលប្រជាពលរដ្ឋមិនអាចទទួលយកបាននៅឡើយ។ ដោយនឿយហត់ខ្លាំងក៏យកក្អើយរុំកមកពាក់ហើយដេកលក់ទៅប្រមាណ១ម៉ោងក្រោយមកមានគេដាស់បំរើបាយល្ងាចខ្នើយរុំកក៏បាត់រកជុំវិញមិនឃើញសោះមានស្រីចិនចំណាស់ម្នាក់រូបក៏អាក្រក់យកខ្នើយខ្ញុំដែលបានធ្លាក់ពេលខ្ញុំដេកលក់យកទៅប្រើសំរាប់គាត់ដេកយ៉ាងរំភើយ រហូតដល់ហុងកុងសូបិនបានសង្កេតរឿងនេះតែមិននិយាយ រហូតជិតដល់ហុងកុងពេលស្រីចំណាស់នោះភ្ញាក់ក៏សួរនាំទោះទើបគាត់ឱ្យមកវិញ។


ជើងយន្តហោះនៅហុងកុង

នៅព្រលានយន្តហោះហុងកុងដែលខ្ញុំខានជួបជាង១០ឆ្នាំមកហើយ ឥឡូវរីកដុះដាលកាន់តែធំធ្វើឱ្យខ្ញុំដែលនឿយហត់មិនបានដេកពួនផង នោះត្រូវដើរច្រើនម៉ាយទុំរាំដល់ជើងដំណើរយន្តហោះចេញមួយទៀត ។ បន្ថែមពីលើនេះនៅលើសំបុត្រយន្តហោះគេភ្លេចមិនបានចារលេខទ្វារជើងដំណើរឱ្យយើងហើយនៅមុនពេលចុះពីយន្តហោះមកដល់ហុងកុងក៏គេមិនបានផ្សាយពីតំណរភ្ជាប់លេខជើងយន្តហោះចេញឱ្យយើងទៀតយើងដើរ១០នាទីហួសទ្វារដែលយន្តហោះយើងចេញតារពិតយើងរកអ្នកដែលឆ្លើយនឹងសំនួរយើងមិនបានសោះយើងទៅខុសកន្លែងដល់មកវិញពេលដឹងថាច្រកទ្វារលេខប៉ុន្មានហើយត្រឡប់មកវិញយន្តហោះបានចេញចោលផុតទៅហើយពេលនោះ ហត់ទាំងឪទាំងម៉ែហើយភាពមួរម៉ៅក៏ផ្តើមដែរ តែកូនវាឥតហត់សោះហើយរត់ជួយរុញឥវ៉ាន់ពួកយើងឥតឈប់ដែរ ។ ចុងបញ្ចប់យើងរកការិយាល័យក្រុមហ៊ុនយន្តហោះកាថេឃើញគឺប្តូរសំបុត្រជើងយន្តហោះបន្ទាប់យឺតពេល១ម៉ោង បានសំបុត្រថ្មី ហើយយើងដើរ១០នាទីទៀត ទើបដល់ទ្វារយន្តហោះថ្មីនោះទាន់ពេលត្រឹមគេផ្តើមបិទទ្វារល្មម ។ នឹកត្រឡប់មកវិញឃើញថា អ្នកបំរើព្រលានយន្តហោះចិនមិនចេះសើចញញឹមទទួលភ្ញៀវទេ ពួកគេមិនត្រឹមតែមិនឆ្លើយសំនួរទេ ថែមទាំងដេញយើងឱ្យទៅមើលក្តារខៀនអេឡិកត្រូនិចដោយខ្លួនឯងក្តារខៀននោះមានអក្សរនឹងលេខដែលលោតលឿនអក្សរចិនលាយនឹងអង់គ្លេសមើលធ្វើឱ្យឈឺក្បាល ព្រោះមើលស្ទើរមិនទាន់ហេតុនេះហើយ សូបិន និយាយថា អ្នកទទួលភ្ញៀវចិននៅឈីកាហ្គោមិនដូចចិននៅហុងកុងនេះទេនៅខាងអាមេរិកឯណោះ គេធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីទាក់ចិត្តភ្ញៀវ រីឯនៅហុងកុងវិញ គេមានចរិកដូចជាមន្ត្រីដែលមានភ្ញៀវជាអ្នកស្តាប់បង្គាប់អីចឹង។ **តទៅទំព័រទី ១៤**


## ផ្តល់កិច្ចបំរើទាំងអស់សំរាប់សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុរបស់លោក -អ្នក

យើងនិយាយភាសាខ្មែរ


**Bopha Malone**
*Branch Relationship Manager, AVP*
430 Gorham Street, Lowell, MA
Bopha.Malone@ebtc.com
978-656-5561


**Sue Suon**
*Branch Service Specialist*
222 Merrimack Street, Lowell, MA
Sue.Suon@ebtc.com
978-656-5679

ក្នុងនាមជាធនាគារសហគមន៍, ធនាគារអ៊ីនធើប្រៃផ្តល់នូវកិច្ចបំរើផ្ទាល់ខ្លួនអតិថិជនមកពីវប្បធម៌ចំរុះ។ យើងអាចជួយលោក -អ្នកចំពោះ សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុទាំងអស់របស់លោក -អ្នក។ ទាំងអស់គ្នា យើងអាចបង្កើតឲ្យមានអាជីវកម្មដែលប្រកបដោយសេចក្តីសំរេច និងសហគមន៍ដ៏រីកចំរើន រស់រវើក។

» ធនាគារផ្ទាល់ខ្លួន
» ធនាគារសំរាប់ជំនួញ
» និក្ខេប
» ការចាត់ចែងផ្នែកវិនិយោគ
» គ្រោងការចូលនិវត្តន៍
» និងជាច្រើនទៀត

សូមនិយាយជាមួយបុគ្គល ម៉ាឡូន ឬស៊ូ សួន ថ្ងៃនេះ
ហើយឲ្យគេជួយលោក -អ្នកបង្កើតឲ្យមានភាពជោគជ័យ!

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com

FDIC

ទស្សនៈ
អ្នកអាន

# ត្រូវនឹងខុស

**ដោយ : តុល ប៊ុន្នី**

មនុស្សយើងមិនគួរធ្វើអ្វីតាមការណែនាំអ្នកនៅជុំវិញខ្លួននៅពេលយើងមិនដឹងហេតុផលច្បាស់លាស់នោះទេ ព្រោះថា បើយើងសម្រេចធ្វើអ្វីខុស កំហុសតូចខាត កំហុសធំខាតធំ ។ នេះក៏ដូចជាការសេពគប់មិត្តភ័ក្តិដែរ សេពគប់មនុស្សល្អ និងបានផលល្អនៅថ្ងៃក្រោយ បើសេពគប់មនុស្សអាក្រក់ មិនទៀងទេ ! ជួនកាលខ្លះល្អសោះទៅសេពគប់ចោរក្លាយទៅជាចោរ ។

សព្វថ្ងៃនៅលើពិភពលោក បច្ចេកវិទ្យាទំនើបធ្វើឱ្យមនុស្សយើងងាយមើលដឹងរឿងស្គាល់ សំខាន់តើយើងចង់ឱ្យខ្លួនយើង កូនចៅយើងជាមនុស្សបែបណា តើយើងចូលចិត្តមនុស្សសុច្ចរិត ឬក៏មនុស្សទុច្ចរិត ។

មនុស្សយើងចិត្តមិនដូចគ្នាទាំងអស់ទេ អ្នកខ្លះចង់បានផលប្រយោជន៍ គិតផលប្រយោជន៍ជាធំ ទោះបីជាដឹងថា ផលប្រយោជន៍នោះ បានមកព្រោះអំពើពុំគប្បីក្តី ឧបមាដូចជាអ្នកខ្លះដើរចូលជាមួយពួកក្រុមម៉ាហ្វីយ៉ាជាដើម បើសិនជាអ្នកមានកូនចៅដើរចូលជាមួយក្រុមស៊ីផឹក អាចដឹកខ្លួនចេញបាន ជាមួយអ្នកល្បែងអាចដកខ្លួនចេញបានអត់បញ្ហា តែបើកូនចៅលោកអ្នក ទៅចូលក្រុមចោរនឹងពួកម៉ាហ្វីយ៉ាវិញ ពេលចង់ដកខ្លួនចេញ គឺបញ្ហាហើយ បញ្ហាធំ គឺបញ្ហាស្លាប់រស់ ។

តើជាការគួរ ឱ្យស្តាយដែរ ឬទេ? ផលប្រយោជន៍ដែលបានមកដោយអំពើទុច្ចរិតមិនថ្លៃថ្នូរទេ! ហើយជាពិសេសសម័យនេះ រឿងរ៉ាវអ្វីមួយដឹងឮរឿងធ្វើល្អល្បីពេញពិភពលោក ! តែបើធ្វើមិនល្អវិញ ក៏ល្បីលឿនដែរ សម័យនេះយើងបើដើរជ្រុលខុសពិតជាស្តាយក្រោយហើយ ។ ព្រោះថាមនុស្សយើងស្លាប់ទៅយកអ្វីទៅមិនបានទេ ដូចជានៅប្រទេសកម្ពុជាយើងសព្វថ្ងៃអ្នកមានមានហួសមានខ្លាំងជាងប្រទេសដែលបង្កើតប្រាក់ដុល្លារទៅទៀត អ្នកដែលមានអំណាចអ្នកដែលជាប់ខ្សែស្រឡាយនឹងអ្នកមានអំណាចគេប្រឹងប្រែងរកវិធីឱ្យមានបាន ទោះបីការមានធ្វើឱ្យមនុស្សរាប់រយនាក់រកទុក្ខវេទនាស្លាប់មុនអាយុអស់ក្តី ធ្វើឱ្យកូនក្មេងរាប់ម៉ឺននាក់ខូចអនាគតវេទនាហួសនឹងថ្លែងក្តី ក៏គេមិនខ្វល់ តើនៅលើពិភពលោកយើងនេះមានអ្វីទៀងទាត់ទេ តើបងប្អូនធ្លាប់បានមើលដឹងឬទេ ? នៅវេបសាយ KI-MEDIA មិនដឹងថា ការពិតឬ អត់? អ្នកសរសេរពីស្តេចគ្រឿងញៀននៅកម្ពុជា ថេង ប៊ុនម៉ា ធ្លាប់ជាមេជួញគ្រឿងញៀននៅថៃ ក្រោយមកមានបញ្ហាមកនៅខ្មែរវិញ មាន Hotel លំដាប់ផ្កាយ៥ មានធនាគារ មានផ្ទះ ល្វែង មានហាងលក់ទំនិញជាច្រើន ក្រោយមកទៅជាអស់អូតែលជុំពាក់មាសគេរាប់រយគីឡូក្រាមមកពីមានអ្នកផ្សេងឆ្លាតជាងគាត់សួរថា អ្នកដែលឆ្លាតជាង ថេង ប៊ុនម៉ា អាចជាស្តេច ឆ្លាយរហូតដែរឬទេ? រឿងនេះអ្នកវិភាគគេហៅថា ពាលស៊ីពាលតាមដានទៅដូចជាសមម្យ៉ាងដែរ ។

តែធ្លាប់ឮអ្នកប្រាជ្ញ ចេះដឹងគេនិយាយថា អ្នកចេះដឹងពិតប្រាកដ គេមិនធ្វើប្រព្រឹត្តរឿងមានកំហុសទេ ! គេថាអ្នកប្រព្រឹត្តកំហុស គឺជាជនឆោតល្ងង់ ?

ដូច្នេះហើយទើបគេឱ្យនិយមន័យថា មនុស្សមិនធ្វើនូវកំហុសគេហៅមនុស្សសុច្ចរិតមនុស្សល្អ ឯមនុស្សចូលចិត្តប្រព្រឹត្តនៅកំហុស ដើម្បីផលប្រយោជន៍នឹងអំណាចវិញ គេហៅមនុស្សអាក្រក់ មនុស្សទុច្ចរិត ។

បើសិននិយមន័យខាងលើ លែងត្រូវលែងមានតម្លៃហើយនៅសម័យនេះ គួរឱ្យអាណិតអាសូរពលរដ្ឋខ្មែរ ដែលក្រីក្រ រងទុក្ខវេទនាយូរសែនយូរមិនដឹងជាពេលណាទើបឆ្លងផុតគ្រោះដែលរស់នៅក្នុងប្រទេសមានឈ្មោះថាធម្មពុជា សូមបួងសួងឱ្យឆ្លងផុតគ្រោះ បានជួបប្រទេសឈ្មោះវង្គត់បូរី ដើម្បីឱ្យបានជួបនូវសេរីភាពពេញលេញ សមនឹងឈ្មោះប្រទេសមានឯករាជ្យផង ៕

***ចុងក្រោយនេះ ខ្ញុំនិយាយតាមពុទ្ធទំនាយ ព្រោះអាណិតខ្មែរពេក ។***


Khmer Owned & Operated

The Joint Commission National Quality Approval

Independence Home Care
Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូទាំងរដ្ឋ

**Licensed Home Care Provider / Companion Services**

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT




*Let our family, take care of yours.*



**CALL US TODAY!**
**(401) 437-8337**
www.independencehs.com
Available 24/7

1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

# ទស្សនះសារព័ត៌មានពីថ្ងៃ១វិច្ឆិកា ដល់១ធ្នូ២០១៤

**ដោយ : ប្រាង់ស្វា ប៉ុងសូ**

**ប្រែសម្រួលពីភាសាបារាំងដោយៈ ខ្មែរផុស សរអា**

**នយោបាយក្នុងស្រុក**

អ្នកវិភាគនយោបាយ កែម ឡី បានបង្កើតចលនាឪខ្មែរដើម្បីខ្មែរតែលោកបានប្រកែកថា មិនមែនសម្រាប់បំបែកគណបក្សប្រឆាំងទេ។ នៅចុងខែតុលា លោកបានចោទ កឹម សុខា ថា ទទួលប្រាក់ខែ១ម៉ឺន៥ពាន់ដុល្លាចម្លើយគណបក្សសង្គ្រោះជាតិ (គសជ) បានអនុញ្ញាត្តិឱ្យដឹងពីប្រាក់ខែអ្នកនយោបាយខ្មែរថាៈ ហេង ស៊ិន បាន ២៣៨៦ ដុល្លាល. កឹម សុខា បាន១.១៨០ បូកនឹងប្រាក់បំណាច់ផ្សេងៗ បានទាំងអស់ ២.៣៧០ដុល្លា។ តំណាងរាស្ត្រធម្មតាបាន៩៧៥ បូកបន្ថែមនឹងប្រាក់បំណាច់ផ្សេងទៀត(ប្រាក់ខែកម្មករ១២៨ដុល្លា)។

កិច្ចចរចារដើម្បីបង្កើត(គជប)ថ្មី គាំងដំណើរគណបក្សប្រជាជន(គបប)បានដាក់ការទាមទារបន្ថែមទៀតៈ គឺមិនឱ្យសមាជិក(គជប)មានសញ្ជាតិ២ ដូច្នេះប៉ះពាល់ដល់បេក្ខភាពលោកស្រី ពុង ឈីវកិច ប្រធានលីកាដូ ដែលគេសង្ឃឹមថានឹងក្លាយជាសមាជិកឯករាជ្យទី៩ កខភាពតែគាត់មានសញ្ជាតិ៣: ខ្មែរ បារាំង កាណាដា។ គបប ទាមទារដំណែងជាប្រធានក្នុងនាមជាគណបក្សកាន់អំណាច តែ គសជ ប្រកែកថា សមាជិក គជប ជាអ្នកជ្រើសរើសប្រធានរបស់គេ។ នៅពេលចរចា



បរាជ័យគជបចាស់នឹងបន្តភារកិច្ចជាបន្តទៅទៀត។

អ្នកសង្កេតការណ៍ជាច្រើននិយាយថា សមរង្ស៊ី ទទួលយកការចរចាថ្ងៃ ២២កក្កដា នោះលឿនពេកមុនពេលរឿងលំអិតបានត្រូវរំដោះរួច ដូច្នេះហើយបានជាអីឡូវនេះគ្មានអាវុធអ្វីនឹងចរចាតទល់គេទៀតទេ។ អារម្មណ៍របស់មូលដ្ឋានពលរដ្ឋសង្គ្រោះជាតិដែលយល់ថា កិច្ចព្រមព្រៀងនោះថាជាអំពើក្បត់មិនច្បាស់ជាខុសប៉ុន្មានទេ។

ថ្ងៃ១១វិច្ឆិការ អាជ្ញាធរបានឃាត់ខ្លួន មាច សុវណ្ណារ៉ា អតីតអ្នកយកពត៌មានអាស៊ីសេរីជាបេក្ខជនសភាជាតិឆ្នាំ២០១៣ឈរនៅបន្ទាយមានជ័យមានបន្ទុកកិច្ចការពត៌មានរបស់គសជ។ លោកត្រូវបានចោទប្រកាន់ពីបទញុះញ៉ុងឱ្យមានហឹង្សានៅពេលបាតុកម្មថ្ងៃ១៥កក្កដា ដែលភស្តុតាងបង្ហាញផ្ទុយទៅវិញ គឺខំទប់កុំឱ្យមានជម្លោះ។ ពិមន្ទីរឃុំឃាំងលោកបានសុំ គសជ កុំបន្ទន់ឥរិយាបទ ចំពោះមុខ គបប ដើម្បីរំដោះលោកចេញពីគុក(ខាំបូឌាដៃលី១១.១៨.១៤)។

ថ្ងៃ១៣វិច្ឆិការ ទេព ណារិន អាយុ៣០ឆ្នាំជាមនុស្សទំនាក់ទំនង គសជ បានត្រូវឃាត់ខ្លួននៅពេលទៅបង្ហាញខ្លួន១៥ថ្ងៃម្តង នៅស្នងការប៉ូលិស ។ លោកត្រូវបានចោទប្រកាន់ថា បានចូលរួមបាតុកម្មហឹង្សាកាលពីថ្ងៃ១៥ធ្នូ (ខែមបូឌាដៃលី ១១.១៤.១៤)

គេរំពឹងថា ការចាប់ចងទាំងនេះគឺជាល្បិចរបស់ គបជ ដើម្បីដាក់សំពាតទៅលើគណបក្សប្រឆាំងនៅក្នុងកិច្ចចរចាគ្នា។ ដូចជាករណីចាប់យុវជន៣នាក់របស់ គសជ នៅ១ខែក្រោយកិច្ចព្រមព្រៀង២២កក្កដា ដើម្បីឱ្យទទួលគម្រោងវិសោធនកម្មស្នើដោយ គបក ដាក់ក្នុងរដ្ឋធម្មនុញ្ញ (ខាមបូឌាដេលីថ្ងៃ១១.១២.១៤)

*កិច្ចព្រមព្រាង២២កក្កដាគ្រោងនឹងផ្តល់

**តទៅទំព័រទី ១៦**


ខូម័រ សិប្បកម្មច្នៃរូបសំណាកគ្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers ផ្នូរផ្តេកមានឆ្លាក់សំរិទ្ធលេចថ្មក្រានីត
- Cemetery Lettering in Khmer មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងលែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# សមត្ថកិច្ច : ឧកញ៉ា ថោង សារ៉ាត់ ជាមេក្លោងសម្លាប់ឧកញ៉ា អ៊ឹង ម៉េងជឺ

- សមត្ថកិច្ចអំពាវនាវដល់កម្លាំងសមត្ថកិច្ច និងមន្ត្រីនៅគ្រប់ច្រកព្រំដែនទាំងអស់សហការតាមចាប់ឧកញ៉ា ថោង សារ៉ាត់
- សមត្ថកិច្ចរកឃើញកាំភ្លើងខ្លី៦ដើមក្នុងភូមិគ្រឹះឧកញ៉ា ថោង សារ៉ាត់
- សមត្ថកិច្ចឃាត់ខ្លួនឪពុក-ម្តាយឧកញ៉ា ថោង សារ៉ាត់ ខណៈលោកឧកញ៉ាបានរត់គេចខ្លួនបាត់ហើយ
- ម៉ោងធ្វើឃាត និងម៉ោងតាមចាប់មេក្លោងស្ថិតក្នុងចន្លោះម៉ោងជាង៧ដូចគ្នា
- អ្នកលេងបណ្តាញសង្គមហ្វេសប៊ុកសាទរចំណាត់ការរបស់លោកស្នងការ ជួន សុវណ្ណ និងទទួចចាប់ឱ្យបានឧកញ៉ាជាមេក្លោង


ខ្មាន់កាំភ្លើង




ជនដៃដល់ដឹកខ្មាន់កាំភ្លើងធ្វើសកម្មភាព




សកម្មភាពសមត្ថកិច្ចឡោមព័ទ្ធ ផ្ទះឧកញ៉ា ថោង សារ៉ាត់

**ភ្នំពេញ :** ឃាតកម្មបាញ់សម្លាប់ឧកញ៉ា អ៊ឹង ម៉េងជឺ កណ្តាលរាជធានីភ្នំពេញ ត្រូវបានវែកមុខហើយបន្ទាប់ពីសមត្ថកិច្ចបើកការស៊ើបអង្កេតរយៈពេល១១ថ្ងៃក្រោយការបាញ់ប្រហារជនសង្ស័យជាមេក្លោង គឺឧកញ៉ា ថោង សារ៉ាត់ ម្ចាស់បុរី៩៩៩។ ឧកញ៉ា ថោង សារ៉ាត់ ជាឧកញ៉ាវ័យក្មេងមួយរូបដែលធ្លាប់មានរឿងរ៉ាវក្តៅគគុកជាច្រើនលើមុខជំនួញរបស់ខ្លួនក្នុងនោះលោកឧកញ៉ាក៏ធ្លាប់មានជម្លោះជាមួយប្រធានសាលាដំបូងរាជធានីភ្នំពេញ អាំង មាលតី រហូត ប្តឹងផ្តល់គ្នាឡើងតុលាការថែមទៀងផង។

ស្នងការរងនគរបាលរាជធានីភ្នំពេញលោកឧត្តមសេនីយ៍ត្រី ជួន ណារិន្ទ បានថ្លែងប្រាប់មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលថា នៅវេលាម៉ោង៧យប់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤នេះ កម្លាំងសមត្ថកិច្ចដឹកនាំដោយព្រះរាជអាជ្ញារងសាលាដំបូងរាជធានីភ្នំពេញ សៀង សុខ កំពុងឡោមព័ទ្ធចាប់ឧកញ៉ាវ័យក្មេង ថោង សារ៉ាត់ នៅភូមិគ្រឹះក្នុងបុរី៩៩៩នៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ។

គ្រាដែលសមត្ថកិច្ចកំពុងប្រតិបត្តិការតាមចាប់ឧកញ៉ា ថោង សារ៉ាត់ ជាមេក្លោងនោះ ជនពាក់ព័ន្ធចំនួន៤នាក់ ជាអង្គរក្សឧកញ៉ាវ័យក្មេងពោរពេញដោយរឿងអាស្រូវ និងក្មេងក្បាងក្នុងរបរជំនួញរូបនេះ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនរួចហើយ។ អង្គរក្សទាំង៤រូបនោះរួមមាន: ទី១។ ឈ្មោះ មាស សម្បត្តិ ទី២។ ឈ្មោះសៀង វាសនា ទី៣។ ឈ្មោះ កូន ចាន់ថុល និងទី៤។ ឈ្មោះ លី សៅ។

ស្នងការនគរបាលរាជធានីភ្នំពេញលោកឧត្តមសេនីយ៍ឯក ជួន សុវណ្ណ ដែលកំពុងបញ្ជាដោយផ្ទាល់នោះ **តទៅទំព័រទី ១១**


# រោងជាង រចនា

**LEGEND AUTO BODY INC.**

អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854

សូមទំនាក់ទំនង **អាដាំ ទ៊ា** : 978-458-2085

**ជួសជុលយានយន្តលោកអ្នកប្រកបដោយគុណភាព**

Lowell Finest Quality of Body Work

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**

- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចជូវ** 978-815-9957 (ខេ-ស៊ី)



**115 Rock St. Unt #7 Lowell, MA 01854**




**AUTO BODY INC.**
**(978) 458-2085**

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)



## តមកពីទំព័រទី ០១ បញ្ហាអន្តោប្រវេសន៍នៅស.រ.អា

អ្នកជំនួយការរបស់លោក បាម៉ា បានថ្លែងថា : យោងទៅតាមការយល់ដឹងរបស់គាត់លោក អូបាម៉ា នឹងមិនមានសិទ្ធិអំណាចធ្វើការបដិសេធចំពោះការគ្រប់គ្រងក្រុមសភាតំណាងរាស្ត្ររបស់គណបក្សសាធារណៈរដ្ឋរួមបញ្ចូលគណបក្សទាំងពីរ ដើម្បីធ្វើការជួសជុលកែតម្រូវច្បាប់ក្នុងព្រឹទ្ធសភា នាពេលកន្លងមកបានធ្វើឱ្យលោក អូបាម៉ា ស្ថិតនៅសភាពឯកោគ្មានវិធីណាផ្សេង ដើម្បីជ្រើសរើសក្រៅពីវិធីដើរតួជាឯកតោភាគីនោះឡើយ ។ លោក អូបាម៉ា បានថ្លែងទៅកាន់សមាជិកក្នុងទីសមាជសភាថា: បើសមាជិកណាមានសំនួរអំពីការប្រើអំណាចបស់ខ្ញុំទៅធ្វើឱ្យប្រព័ន្ធអន្តោប្រវេសន៍មានដំណើរការប្រសើរឡើង ឬមានសំនួរពីភាពវៀងវៃរបស់ខ្ញុំបានធ្វើឱ្យសមាជសភាទទួលភាពបរាជ័យ ខ្ញុំនឹងមានចម្លើយមួយគឺ "សេចក្តីព្រាងច្បាប់បានចប់ហើយ" ។

វិធានការណ៍របស់លោក អូបាម៉ា បានបញ្ឈប់ការគម្រាមធ្វើនិរទ្ទេសជនភៀសខ្លួនរាប់លាននាក់ ដោយរាប់បញ្ចូលអ្នកដែលទទួលបានការការពារបណ្តោះអាសន្នមានចំនួន៤លាន១០ម៉ឺននាក់ អនុញ្ញាតិឱ្យរកការធ្វើដោយស្របច្បាប់ឆ្លងកាត់ការពិនិត្យប្រវត្តិរូបមានក្មេងនឹងទារកដែលបាននាំចូលមកស.រ.អាដោយខុសច្បាប់មានចំនួន២៧ម៉ឺននាក់ ។

ក្នុងពេលជាមួយគ្នានេះដែរ លោក អូបាម៉ា បានប្រកាសផែនការណ៍មួយបង្កើនការរក្សាសន្តិសុខតាមព្រំដែននឹងបង្វិលការយកចិត្តទុកដាក់ក្នុងមហាផ្ទៃនៃ ស.រ.អា វិធានការណ៍របស់លោក អូបាម៉ា ស្ទើរតែប្តូរផ្លាស់ទាំងស្រុងចំពោះគោលនយោបាយអន្តោប្រវេសន៍យោងទៅតាមសមាជសភាធ្លាប់មានពីមុនមក ។

តាំងពីសម័យកាលឆ្នាំ១៩៨០ ប្រធានាធិបតី រ៉ូណូល រ៉ុហ្គ្រិន (Ronald Reagan) បានយល់ស្របទៅតាមគោលនយោបាយអន្តោប្រវេសន៍បានហូរចូលមកស.រ.អាមានទាំងអ្នកចូលដោយស្របច្បាប់ និងធ្វើឱ្យមានការផ្លាស់ប្តូរបែងចែកវប្បធម៌ក្នុងស.រ.អា និងមិនព្រមធ្វើត្រាប់តាមដំណោះស្រាយនៃកិច្ចការនយោបាយជាដើម ។

សព្វថ្ងៃនេះ ជនអន្តោប្រវេសន៍ដោយខុសច្បាប់មានប្រមាណ១៣លាននាក់ ក្នុងស.រ.អា គណបក្សទាំងពីរបានរំពឹងថា : គួរតែនិរទ្ទេសពួកគេទាំងនោះចេញ ។

លោកប្រធានាធិបតី អូបាម៉ា បានថ្លែងថា : គាត់នឹងធ្វើកិច្ចការជួសជុលប្រព័ន្ធអន្តោប្រវេសន៍ដែលបានបាក់បែកនោះដោយខ្លួនឯង ជំនួសឱ្យគណបក្សទាំងពីរមិនមែនសម្រាប់តែគណបក្សប្រធានាធិបតីឡើយ ។

អ្នកនាំពាក្យរដ្ឋាភិបាល ចន បូអីនើ រ៉ូហៃអូ (John Boehner. Rohio) បានមានប្រសាសន៍ថា "លោកប្រធានាធិបតីមិនមែនជាស្តេចមិនមែនជាអធិរាជ្យ ប៉ុន្តែគាត់មានវិធានការណ៍មិនខុសពីច្បាប់ ឬអធិរាជ្យនោះទេ គាត់នឹងអនុវត្តន៍នៅពេលណាដែលប្រជារាស្ត្រអាមេរិកាំងគ្មានបំណងអ្វីក្រៅពីការរួបរួមជាមួយគ្នាធ្វើឱ្យមានដំណើរការទៅមុខ ។



លោក មីុក ម៉ាកខនណែវ អរឃី (Mitch McConnell R.Ky) អ្នកនាំមុខព្រឹទ្ធសភា (រៀបទទួលតំណែង) បានមានប្រសាសន៍ថា : លោកប្រធានាធិបតី អូបាម៉ា នឹងត្រូវចារជាប់វិប្បដិសារីចូលទៅក្នុងទំព័រប្រវត្តិសាស្ត្រ ប្រសិនបើជាវិធានការណ៍របស់លោកមិនធ្វើដំណើរទៅមុខបាន ។

អ្វីដែលលោក អូបាម៉ា រៀបចំឡើងនោះគឺប្រជាមតិសំរាប់ការបោះឆ្នោតឆ្នាំ២០១៦ ចំពោះក្រុមបេក្ខជនអាណត្តិក្រោយតម្រូវឱ្យពួកគេធ្វើកិច្ចសន្យាបន្តគោលនយោបាយលោកអូបាម៉ា ឬត្រូវបញ្ចប់ ប្រសិនបើពួកគេឆ្លើយថា ត្រូវបញ្ចប់នោះនឹងមានការទាមទារឱ្យពួកគេឆ្លើយនៅសំនួរថា តើពិតជាមានការចាប់ផ្តើមធ្វើការនិរទ្ទេសប្រជារាស្ត្ររាប់លាននាក់មែនឬទេ? រួចហើយប្រជារាស្ត្រទាំងនោះគេធ្វើការយ៉ាងណាទៅក្រុមមន្ត្រីរាជការមានក្តីសង្ឃឹមថា ប្រធានាធិបតីអាណត្តិក្រោយទោះបីមកពីគណបក្សណាក៏ដោយប្រហែលជាមិនដកហូតនៅផលប្រយោជន៍ដែលធ្លាប់បានផ្តល់ឱ្យជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនោះទេ ។

កិច្ចការរបស់លោក អូបាម៉ា ជានិមិត្តរូបផ្ទុយចំពោះការដាក់សម្ពាធទៅលើអ្នកគាំទ្រច្បាប់អន្តោប្រវេសន៍ធ្វើការទប់ស្កាត់ការនិរទ្ទេសដែលបានទទូចចង់ធ្វើលោក អូបាម៉ា មិនអាចប្រតិបត្តិទៅតាមកំណែទម្រង់គ្រង់ចំណុចខ្លះដែលពុំបានកែប្រែនោះឡើយ ។

លោកអគ្គលេខាធិការសារព័ត៌មានប្រចាំសេតវិមាន ចូស្ហ អៀនែន (Josh Earnest) បានថ្លែងថា : មានពេលខ្លះលោក អូបាម៉ា បានសាកសួរទៅក្រុមការងាររបស់គាត់ឱ្យធ្វើការសើរើឡើងវិញ នៅច្បាប់អន្តោប្រវេសន៍ដែលមានពីមុនមកពិនិត្យមើលឯកសារសំខាន់ៗរបស់លោកដោះស្រាយឱ្យបានស្របច្បាស់លាស់នៅបណ្តាបញ្ហាដែលបានជាប់គាំងឱ្យបានរួចរាល់ព្រោះយើងត្រូវចាកចេញក្នុងរយៈពេលខ្លីខាងមុខ ។

លោក អូបាម៉ា និងក្រុមអ្នកជំនួយការណ៍របស់គាត់ចង់ធ្វើនូវកិច្ចការរបស់បុព្វការីជនជាច្រើនធ្លាប់បានធ្វើរួចមកហើយ លោកបានថ្លែងថា: "អ្វីដែលខ្ញុំបានធ្វើមិនមែនគ្រាន់តែជាការស្របច្បាប់ប៉ុណ្ណោះទេ វាជាលក្ខណៈអនុវត្តន៍ទៅតាមអតីតកាលប្រធានាធិបតីទាំងពីរគណបក្សសាធារណៈរដ្ឋ និងប្រជាធិបតេយ្យក្នុងអំឡុងពេលកន្លះសតវត្ស(៥០ឆ្នាំ) មកនេះ ។

គណបក្សសាធារណរដ្ឋបានប្រកាន់លោក អូបាម៉ា ថា: បានប្រើអំណាចធ្វើការហួសប្រមាណពីនិតិប្រតិបត្តិរបស់ខ្លួន ហើយក៏បានធ្វើការព្រមានថា ពួកគេពុំអាចរងចាំដល់ពេលគណបក្សសាធារណៈរដ្ឋធ្វើកិច្ចប្រជុំសភាដើម្បីទទួលដំណែងថ្មីក្នុងខែមករាខាងមុខនេះបានឡើយ ពីព្រោះគាត់ជា(ថ្នាំពុល) ពាក្យប្រៀបធៀបថា នឹងធ្វើឱ្យខូចកិច្ចការសម្របសម្រួលជារៀងរាល់លើក ។

រឿងហេតុដែលរៀបរាប់ខាងលើបានធ្វើឱ្យគណបក្សសាធារណៈរដ្ឋខឹងយ៉ាងខ្លាំងរួចបាននិយាយថា : ពួកគេនឹងរកមធ្យោបាយដើម្បីកាត់ផ្តាច់កម្មវិធីផ្តល់ថវិការ ប៉ុន្តែក្រុមមន្ត្រីរាជការបានបញ្ជាក់ថា : រឿងនោះឋិតនៅលើកិច្ចសមាជសភាធ្វើការកាត់ថ្លៃថវិការសម្រាប់បំរុងទុក ៕


**KhmerPost USA, LLC**

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម Advertising

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Contributed Writers:

Kim Phien, Richard Howe,Jr.

ច្នៃសោភ័ណភាពកាសែត Design Artist

Heng Chhunleng

នាយករដ្ឋបាល Office Manager 978-677-7163

Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.


The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# មេធាវីថីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts



# អាថ៌កំបាំងធ្វើ ឱ្យស្បែកស្អាត

1. ព្យាយាមទទួលទានទឹកក្នុងមួយថ្ងៃឱ្យបាន៨កែវ ព្រោះជាតិទឹកវាជួយសម្រួលប្រព័ន្ធទាំងអស់នៅក្នុងរាងកាយឱ្យមានដំណើរល្អ ។ ដូច្នេះធ្វើយ៉ាងណាព្យាយាមទទួលទានទឹកឱ្យបាន៨កែវក្នុងមួយថ្ងៃ ដើម្បីជួយរក្សាសំណើមដល់ស្បែក ព្រមទាំងជួយកម្ចាត់សារជាតិពុលពីរាងកាយបានទៀតផង ។

2. ជ្រើសរើសទទួលទានបន្លែផ្លែឈើ និងត្រីឱ្យបានច្រើនជាងគេ ពីព្រោះវាមានសារសំខាន់ចំពោះសុខភាពស្បែក ។

3. ឡេការពារកម្ដៅថ្ងៃនៅក្នុងកម្ដៅថ្ងៃមានផលអាក្រក់ជាច្រើនបំផ្លាញដល់ស្បែក ក្នុងនោះមិន ថាកាំរស្មី UVA UVB ដូច្នេះទោះបីស្ថិតក្នុងស្ថានភាពអាកាសធាតុបែបណាក៏ដោយ គួរជ្រើសរើសប្រើឡេការពារកម្ដៅថ្ងៃមានកម្រិត spf 30 ព្រមទាំងចៀសវាងកម្ដៅចាប់ពីម៉ោង១១:00-១៥:00 ព្រោះអំឡុងពេលនេះកម្ដៅថ្ងៃនឹងបំផ្លាញស្បែកអ្នកបាន ៕

GREATER LOWELL
CHAMBER OF COMMERCE
131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

A resource for your business or organization!
Networking Events
Seminars
Resources
TV & Radio Shows
And more!

សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក
ព្រឹត្តិការណ៍ទំនាក់ទំនង
សន្និសីទ
ធនធាន
កម្មវិធីទូរទស្សន៍ និងវិទ្យុ
និងនៅមានច្រើនទៀត

ភោជនីយដ្ឋាន សុភមង្គលថ្មី
New Happiness Restaurant
Open from 7:30AM-9:00PM











គុយទាវអូរឫស្សី
ម្ហូបខ្មែរពិត។
ម្ហូបដែលភ្ញៀវតែងចូលចិត្តពិសារ
- សេវាល្អ
- តម្លៃសមរម្យ
- កន្លែងចតឡានមុខក្រោយ

អាស័យដ្ឋាន: 6 Branch Street Lowell. MA 01851
ទូរស័ព្ទ : (978) 454-4727

## តមកពីទំព័រទី ០៧ សមត្ថកិច្ច : ឧកញ៉ា ថោង សារ៉ាត់...

បានថ្លែងថា កម្លាំងសមត្ថកិច្ចកំពុងចូលឆែកឆេរនៅក្នុងភូមិគ្រឹះតែមិនទាន់ចាប់បានឧកញ៉ាជាមេក្លោងនៃការបាញ់ប្រហារកណ្តាលរាជធានីភ្នំពេញនៅឡើយទេ។

បើតាមសមត្ថកិច្ចបានបញ្ជាក់ថា រហូតដល់ម៉ោង៨ និង១៣នាទីយប់ថ្ងៃដដែលនេះ សមត្ថកិច្ចបានឃាត់ខ្លួនឪពុក-ម្តាយ របស់ឧកញ៉ា ថោង សារ៉ាត់ ខណៈលោកឧកញ៉ាបានរត់គេចខ្លួនបាត់ហើយ។ ឪពុករបស់លោកឧកញ៉ា ថោង សារ៉ាត់ មានឈ្មោះ តាំង សុខ ហៅថោង ចំរើន អាយុ៦៥ឆ្នាំ រីឯម្តាយមានឈ្មោះ កែវ សារី អាយុ៥៥ឆ្នាំ ជាមន្ត្រីក្រសួងការពារជាតិ។

រហូតដល់វេលាម៉ោង៩ និង២១នាទីយប់ កម្លាំងសមត្ថកិច្ចបានចុះទៅឆែកឆេរទីតាំងក្រុមហ៊ុនចែកចាយសាច់បាត់តេ នៅក្នុងសង្កាត់បឹងទំពន់ដែលជារបស់លោកឧកញ៉ា ថោង សារ៉ាត់ តែរកមិនឃើញលោកឧកញ៉ាទេ។ ក្នុងប្រតិបត្តិការឆែកឆេរនាយប់នេះ សមត្ថកិច្ចបានរកឃើញកាំភ្លើងខ្លី៦ដើមនៅក្នុងភូមិគ្រឹះរបស់ឧកញ៉ា ថោង សារ៉ាត់ ក្នុងសង្កាត់ចាក់អង្រែក្រោម។

ជាមួយនិងប្រតិបត្តិការឆែកឆេររកមិនឃើញឧកញ៉ា ថោង សារ៉ាត់ នោះ កម្លាំងនគរបាលរាជធានីភ្នំពេញបានអំពាវនាវដល់អាជ្ញាធរ និងសមត្ថកិច្ចនៅតាមច្រកព្រំដែនទាំងអស់ចូលរួមសហការធ្វើយ៉ាងណាឃាត់ឱ្យបានលោកឧកញ៉ា ថោង សារ៉ាត់ ប្រសិនបើឃើញលួចគេចខ្លួនទៅប្រទេសដទៃតាមច្រកព្រំដែន។

គ្រាសមត្ថកិច្ចកំពុងញាប់ដៃញាប់ជើងឆែកឆេរតាមចាប់ជនសង្ស័យជាមេក្លោងនោះ ប្រជាពលរដ្ឋខ្មែរលើបណ្តាញសង្គមហ្វេសប៊ុកបានសម្តែងការភ្ញាក់ផ្អើលយ៉ាងខ្លាំងជុំវិញការបំបែកសំណុំរឿងឃាតកម្មមួយនេះ ក្នុងរយៈពេលត្រឹមតែ១១ថ្ងៃ និងបានកោតសរសើរយ៉ាងខ្លាំង ចំពោះស្នាដៃ និងជំនាញបច្ចេកទេសស្រាវស្រាវរបស់សមត្ថកិច្ច។ ក្រុមអ្នកលេងហ្វេសប៊ុក ក៏បានទទូច និងបួងសួងឱ្យចាប់បានជនសង្ស័យជាមេក្លោងមកវិនិច្ឆ័យទោសផងដែរ។

ជាការកត់សម្គាល់ប្រតិបត្តិការតាមចាប់ខ្លួនឧកញ៉ា ថោង សារ៉ាត់ ដែលជាប់សង្ស័យជាមេក្លោងនៅពីក្រោយឃាតកម្មបាញ់សម្លាប់ឧកញ៉ា អ៊ឹង ម៉េងជឺ បានធ្វើឡើងភ្លាមៗ ពោលរយៈពេលប្រហែលជា ២-៣ម៉ោងប៉ុណ្ណោះ បន្ទាប់ពីឪពុក-ម្តាយរបស់លោកឧកញ៉ា ថោង សារ៉ាត់ បានហៅអ្នកព័ត៌មានជាច្រើនស្ថាប័នទៅធ្វើសន្និសីទព័ត៌មានលាងសម្អាតកេរ្តិ៍ឈ្មោះលោកឧកញ៉ា និងអង្គរក្សថា មិនមានជាប់ពាក់ព័ន្ធនឹងឃាតកម្ម។ ក្នុងសន្និសីទព័ត៌មាននេះ អ្នកស្រី កែវ សារី ជាម្តាយឧកញ៉ា ថោង សារ៉ាត់ បានតវ៉ាមប្តឹងបកទៅសមត្ថកិច្ចថែមទៀតផង ដែលបានចាប់លោកឧកញ៉ា និង អង្គរក្ស។

សូមបញ្ជាក់ថា លោកឧកញ៉ា អ៊ឹង ម៉េង ជៅ កែស៊ីម៉ង់តីពេជ្រ និងជាម្ចាស់ហាងពេជ្រហុងកុង ត្រូវបានឃាតកបាញ់សម្លាប់មិនប្រណីដៃបណ្តាលឱ្យដេកដួលស្លាប់ក្នុងថ្លុកឈាម កាលពីវេលាម៉ោងជាង៧យប់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៤ ពេលលោកចុះទិញផ្លែឈើនៅជិតស្តាតអូឡាំពិក ក្នុងសង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន។

សូមរំលឹកផងដែរថា លោកឧកញ៉ា ថោង សារ៉ាត់ ធ្លាប់មានរឿងក្តីក្តាំជាច្រើនជាមួយដៃគូជំនួញរបស់ខ្លួនក្នុងនោះ លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ អាំង មាលតី ក៏ធ្លាប់មានរឿងក្តីក្តាំប្តឹងផ្តល់គ្នាផងដែរ៕





## តមកពីទំព័រទី ០១ ពាណិជ្ជកម្មចុងឆ្នាំសាកល

ដៃអ្នកទិញទៅអ្នកលក់ពីអ្នកលក់រាយទៅអ្នកលក់ដុំពីអ្នកលក់ដុំទៅរោងចក្រពីរោងចក្រទៅកម្មករពីកម្មកររោងចក្រទៅអ្នកលក់សារជាថ្មីឡើងវិញ។ ចរន្តនៃលុយក្នុងវប្បធម៌សេដ្ឋកិច្ចមានរូបជារង្វង់មូលវិលទៅវិលមកដែលអ្នកប្រាជ្ញសេដ្ឋកិច្ចនិយាយថា តែវិលលឿនពេលណាភាពរីកចំរើនកើតឡើងពេលនោះ ដូចជារាល់ពេលចុងឆ្នាំនេះចរន្តលុយវិលលឿនណាស់ ហើយទាំងអ្នកលក់នឹងអ្នកទិញអាមេរិកាំងសប្បាយចិត្តទាំងអស់គ្នា។

ប្រៀបធៀបទៅនឹងវប្បធម៌សេដ្ឋកិច្ចសង្គមខ្មែរយើងច្រើនចងចាំបន្តពីចាស់ទុំដែលប្រដៅឱ្យសន្សំកុំទិញរបស់ផ្តេសផ្តាសរស់នៅត្រឹមគ្រប់គ្រាន់ទិញខោអាវស្បែកពាក់១ឆ្នាំម្តង ឬ២ដង នារដូវចូលឆ្នាំនឹងភ្ជុំបិណ្ឌ ទៅហូបអាហារនៅក្រៅផ្ទះម្តងម្កាលដោយមេផ្ទះមិនមានឃើញការចាំបាច់ណាមួយ បើនឹងទិញអ្វីមួយត្រូវចាយលុយឱ្យបានតិចមិនចាំបាច់ល្អពេកទេ ឱ្យតែមានប្រើទៅបានហើយ ។ល។ តែមកដល់សហរដ្ឋនេះគ្រួសារខ្មែរយើងប្រឈមមុខនឹងសង្គមអ្នកចាយអ្នកប្រើប្រាស់របស់របរ Consumer society ទាល់តែចាយ ទើបចំរើនទាល់តែពូកែទាល់តែស្អាតទាល់តែទំនើប ទាល់តែគេចាប់អារម្មណ៍ ទើបងើបមុខធ្វើការរកស៊ីនឹងគេចុះ ម្ល៉ោះហើយកូនចៅយើងមានការច្របូកច្របល់ក្នុងចិត្តយល់ថាគំនិតណាមួយក៏ត្រូវ សន្សំរបស់ចាស់ក្រែងប្រើបាននៅថ្ងៃមុខទិញរបស់ថ្មីមកប្រើក្រែងលេចពេក។ ដូច្នេះហើយបានជាគេឃើញអ្នករៀបផ្ទះពិបាករៀបឱ្យសមស្បែកខោអាវពិបាករកម៉ូដស៊ីគ្នាធ្វើឱ្យយើងមិនសប្បាយចិត្តកើតវិលវល់មិនចេះចប់ធ្វើការសម្រេចចិត្តអ្វីមួយមិនបាន ខ្លះមានទំនាស់ក្នុងផ្ទះថែមទៀត។

វប្បធម៌អាមេរិកាំងដែលយើងរស់ជាមួយរាល់ថ្ងៃគេបានយកវប្បធម៌គេទៅរៀបជារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមផ្លូវឆ្ងាយដ៏រឹងមាំឱ្យប្រជាជាតិរបស់គេដែលខ្មែរអាមេរិកាំង ក៏នៅក្នុងនោះដែរ គឺការមិនប្រឹងរស់តែម្នាក់ឯងគេបង្កើតកាងារឱ្យគេសន្សំលុយឱ្យគេធានាសុខភាពឱ្យគេធានាកម្មវិធីសាលារៀនឱ្យគេធានាយុត្តិធម៌សង្គមឱ្យ ។ល។ ទាំងអស់នោះយើងមិនអាចភ្លើតភ្លើនប៉ះពាល់វាមុនពេលត្រូវការចាំបាច់បាននោះទេ ដូច្នេះលុយដែលសល់ក្នុងដៃយើងវិញ យើងអាចចាយវាយសម្រាប់ជាការសប្បាយចិត្តបំពេញចិត្តខ្លួនឯងបានខ្លះហើយ ដូចជារីករាយនាឱកាសចុងឆ្នាំនេះ ទិញទិញឱ្យកាដូឱ្យបំពេញចិត្តកូនចៅអ្នកផ្ទះញាតិមិត្តរីករាយនឹងរៀបឆ្នាំថ្មីឱ្យជីវិតរីតតែប្រសើឡើង។

សហគមន៍ខ្មែរ គួរចាប់អារម្មណ៍ពិភាក្សាការកែតម្រូវអត្ថន័យវប្បធម៌សេដ្ឋកិច្ចខ្មែរអាមេរិកាំងនេះឱ្យបានច្រើនដែលខ្មែរផុសស.រ.អាយល់ថា យោបល់ខ្លួនពេលនេះមិនច្បាស់ជាប្រសើនោះទេ ដូចសូមប្រិយមិត្តអ្នកអានមេត្តាចូលរួមយោបល់ ទោះតិចក្តីច្រើនក្តីទំព័រយើងសូមស្វាគមន៍។

ឆ្នាំនេះក៏ដូចឆ្នាំមុនៗ បងប្អូនខ្មែរអាមេរិកាំងបានត្រៀមរៀបចំទទួលឆ្នាំ២០១៥នឹងមានការស៊ីផឹកតាមផ្ទះយ៉ាងអ៊ឹកធឹកដូចរាល់ឆ្នាំ ខុសតែតំបន់សេដ្ឋកិច្ចខ្មែរនៅតំបន់"ក្រុងខ្មែរ"ហាក់ពុំទាន់មានការរៀបចំណាមួយ គួរឱ្យទាក់ទាញអារម្មណ៍រីករាយសម្រាប់ខែដាច់ឆ្នាំនេះនៅឡើយទេ៕


MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៤ ខែធ្នូ ឆ្នាំ២០១៤

# លោក ហ៊ុន សែន និងលោក សម រង្ស៊ី ដោះស្រាយបញ្ចប់ការខ្វែងគំនិតគ្នាលើការធ្វើកំណែទម្រង់បោះឆ្នោត

**ដោយ គុច ណារ៉េន** | **NOVEMBER 29, 2014**

នៅក្នុងជំនួបមួយកាលពីថ្ងៃសុក្រនៅឯរដ្ឋសភា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងបានដោះស្រាយវិវាទដែលនៅសេសសល់រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិជុំវិញសេចក្ដីលម្អិតអំពីកំណែទម្រង់ដ៏មានសារៈសំខាន់ដូចដែលបានសន្យាគ្នានៅក្នុងកិច្ចព្រមព្រៀងនយោបាយកាលពីថ្ងៃទី២២ ខែកក្កដា រវាងគណបក្សទាំងពីរ។

លិខិតមួយដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃសុក្រ ដោយលោក ហ៊ុន សែន និងលោក សម រង្ស៊ី ដែលបានជួបគ្នានៅខាងក្រៅសម័យប្រជុំសភាពេញអង្គលើកឡើងថា សេចក្ដីព្រាងច្បាប់ថ្មីមួយស្ដីពីការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) និងការធ្វើវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតដែលមានស្រាប់នឹងត្រូវអនុម័តត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០១៥។

លិខិតនេះមានខ្លឹមសារដូច្នេះថា "សម្រាប់ការខ្វែងគំនិតគ្នាដែលនៅសេសសល់លើសេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប. មេដឹកនាំកំពូលៗនៃគណបក្សទាំងពីរបានព្រមព្រៀងដោះស្រាយវាទាំងស្រុង"។

បន្ទាប់ពីជំនួបនេះ លោក គួយ ប៊ុនរឿន ប្រធានក្រុមចរចារបស់គណបក្សសង្គ្រោះជាតិទទួលបន្ទុកការចរចាលើបញ្ហាកំណែទម្រង់បោះឆ្នោតបានមានប្រសាសន៍ទៅកាន់ក្រុមអ្នកយកព័ត៌មានថា គណបក្សប្រឆាំងបានទទួលយកការទាមទាររបស់គណបក្សប្រជាជនកម្ពុជាដែលសុំឱ្យហាមឃាត់សមាជិកគ.ជ.ប.មិនឱ្យមានសញ្ជាតិពីរ។

លោកមានប្រសាសន៍ថា "ពាក់ព័ន្ធនឹងបញ្ហាសញ្ជាតិសម្រាប់សមាជិករបស់គ.ជ.ប.យើងមិនដាច់អហង្ការពេកនោះទេ។ វាមានន័យថា អ្នកដែលចង់ធ្វើជាបេក្ខជនត្រូវបោះបង់សញ្ជាតិផ្សេងទៀតចោលបន្ទាប់ពីជាប់ឆ្នោត"។

លោកបានមានប្រសាសន៍ទៀតថា សមាជិក គ.ជ.ប. អាចដាក់ពាក្យសុំសញ្ជាតិបរទេសវិញបាននៅពេលពួកគេចាកចេញពីមុខតំណែងរបស់ខ្លួននៅក្នុងគណៈកម្មាធិការបោះឆ្នោតដែលមានសមាជិកប្រាំបួនរូបនេះ។

លោក កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌មកពីគណបក្សប្រជាជនកម្ពុជាដែលបានមានប្រសាសន៍ទៅកាន់ក្រុមអ្នកយកព័ត៌មានក្រោយពីជំនួបនេះបានឱ្យដឹងថា ច្បាប់ថ្មីនេះក៏នឹងតម្រូវឱ្យអគ្គលេខាធិការ និងមន្ត្រីផ្សេងទៀតរបស់គ.ជ.ប.ត្រូវបានអនុម័តដោយសំឡេងឆ្នោតភាគច្រើនក្នុងចំណោមសមាជិកទាំងប្រាំបួនរូបផងដែរ។

ពីមុនគណបក្សប្រជាជនកម្ពុជាបានជំរុញឱ្យផ្ដល់សិទ្ធិអំណាចដល់ប្រធាន គ.ជ.ប.ជាអ្នកចាត់តាំងរដ្ឋបាលរបស់ស្ថាប័ននេះដោយផ្ទាល់។

លោក កើត រិទ្ធ បានមានប្រសាសន៍ថា គណបក្សសង្គ្រោះជាតិក៏បានទទួលយកការទាមទាររបស់គណបក្សប្រជាជនកម្ពុជាដែរ ដែលសុំឱ្យសមាជិក គ.ជ.ប.មិនមែនជាញាតិលោហិតរបស់ប្រធាន ឬអនុប្រធានបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា។

គ.ជ.ប.ថ្មីនេះនឹងមានសមាសភាពសមាជិកបួនរូប ដែលជ្រើសតាំងដោយគណបក្សប្រជាជនកម្ពុជាបួនរូបជ្រើសតាំងដោយគណបក្សសង្គ្រោះជាតិ និងសមាជិកអព្យាក្រឹតទី៩មួយរូបទៀត។ លោក កើត រិទ្ធ បានមានប្រសាសន៍ថា មេដឹកនាំគណបក្សបានព្រមព្រៀងគ្នាលើយន្តការមួយដើម្បីបំបែកភាពជាប់គាំងណាមួយដែលអាចកើតមាននៅក្នុងគណៈកម្មាធិការបោះឆ្នោតនេះ។

លោកបានមានប្រសាសន៍ថា "ក្នុងករណីដែល គ.ជ.ប. ជាប់គាំង និងបង្កជាឧបសគ្គដល់ការរៀបចំការបោះឆ្នោតរដ្ឋសភាអាចរម្លាយ គ.ជ.ប.បានតាមរយៈសំឡេងឆ្នោតឱ្យភាគច្រើន"។

ជាការប្ដូរចិត្តរបស់រដ្ឋាភិបាល លោក ហ៊ុន សែន ក៏បានយល់ព្រមអនុញ្ញាតឱ្យគណបក្សសង្គ្រោះជាតិបើកស្ថានីយទូរទស្សន៍អាណាឡូក (Analog) មួយផងដែរ ជាការបំពេញសន្យាដែលលោកបានធ្វើឡើងជាផ្នែកនៃកិច្ចព្រមព្រៀងថ្ងៃទី២២ កក្កដា។ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍ កាលពីថ្ងៃព្រហស្បតិ៍ថា គ្មានស្ថានីយទំនេរសម្រាប់គណបក្សប្រឆាំងឡើយ។

ស្ថានីយទូរទស្សន៍របស់គណបក្សប្រឆាំងនឹងត្រូវគ្រប់គ្រងដោយក្រុមហ៊ុនឯកជនមួយដែលមានឈ្មោះថា ខេមបូឌា អ៊ិនឌីផេនដេន មេឌា (Cambodia Independent Media) ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចរាល់ហើយ ហើយនឹងទទួលបានប្រេកង់មួយដែលបច្ចុប្បន្នគេ

តទៅទំព័រទី១៥

# Hun Sen, Rainsy Settle Differences in Reform Deal

**BY KUCH NAREN | NOVEMBER 29, 2014**

Prime Minister Hun Sen and opposition leader Sam Rainsy, in a meeting on Friday at the National Assembly, settled the remaining disputes between the CPP and CNRP over the details of the sweeping electoral reform package promised in their July 22 political deal.

A letter signed Friday by Mr. Hun Sen and Mr. Rainsy, who met on the sidelines of a plenary session of parliament, says a new draft law on the organization of the National Election Committee (NEC) and an amendment to the existing election law will be passed by the end of February 2015.

"For the remaining disagreements in the draft law on the organization and functioning of the NEC, the top leaders of the two parties agreed to settle them completely," the letter says.

Speaking to reporters after the meeting, Kuoy Bunroeun, one of the CNRP's lead negotiators in election reform talks, said the opposition party had given in to the CPP's demand that members of the NEC be barred from holding dual citizenship.

"Regarding the matter of nationality for all members of the NEC, we are not extremely intransigent," Mr. Bunroeun said. "It means that those who want to be candidates shall renounce other nationalities after being voted in."

Mr. Bunroeun said that NEC members would be able to reclaim foreign citizenship once they left their position on the nine-member committee.

The new law will also require the NEC's secretary-general and other officials to be approved by a majority vote among the nine members, according to Keut Rith, a CPP secretary of state at the Justice Ministry who also addressed reporters following the meeting.

The CPP had previously been pushing for the NEC president to be given the power to personally appoint the body's administration.

Mr. Rith said the CNRP had also accepted the CPP's demand that members of the NEC cannot be blood relatives of the leader or deputy leader of parties with seats in the National Assembly.

The new NEC will be composed of four members appointed by the CPP, four by the CNRP and a ninth neutral member. Mr. Rith said the party leaders had agreed on a mechanism to break any potential impasse within the electoral commission.

"In case the NEC is deadlocked and is causing obstacles to the organization of an election, the National Assembly can dissolve the NEC by a [majority] vote," Mr. Rith said.

In a change of heart by the government, Mr. Hun Sen also agreed to let the CNRP operate an analog TV station, fulfilling a promise he made as part of the July 22 deal. Information Minister Khieu Kanharith said Thursday that there were no available stations for the opposition party.

The opposition TV station will be run by a private company called Cambodia Independent Media, which has already been registered with the Ministry of Commerce, and will be given a frequency that is currently unused, according to a letter from Mr. Kanharith released Friday and dated Thursday.

"Cambodian Independent Media Co., Ltd. shall come and submit an application with the Ministry of Information for a license to operate a television station in Phnom Penh municipality and relay-broadcasting in the provinces," the letter says.

Speaking by telephone Friday, Mr. Rainsy said that Mr. Hun Sen had called him Thursday night to inform him that the Information Ministry's insistence that the opposition start a digital TV channel, rather than an analog station, was in violation of the July deal.

"Last night at midnight, Hun Sen called me and said he recognized it is not fair and that, 'The government will find a way for you to have the analog TV station that you can operate right now,'" Mr. Rainsy said.

Also as part of Friday's deal, Mr. Hun Sen agreed to officially recognize Mr. Rainsy as the "minority leader" in the National Assembly, a title that the opposition leader said was "just an honorific, but at least it is symbolic."

Mr. Rainsy said that Mr. Hun Sen

**Continued to Page 15**

ឌឹ ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៤ ខែធ្នូ ឆ្នាំ២០១៤

## មនុស្សប្រាំមួយនាក់ស្លាប់បន្ទាប់ពីផឹកស្រាសដែលសង្ស័យថាមានជាតិពុល

**ដោយ បែន សុខហ៊ាន** | NOVEMBER 25, 2014

ក្រុមមន្ត្រីបាននិយាយកាលពីម្សិលមិញថា មនុស្សប្រាំមួយនាក់បានស្លាប់នៅក្នុងភូមិមួយក្នុងខេត្តក្រចេះ រយៈពេលពីរសប្តាហ៍មុនបន្ទាប់ពីផឹកស្រាសដែលអាជ្ញាធរមូលដ្ឋានសង្ស័យថា មានជាតិពុល។

ការស្លាប់ដំបូងកើតឡើងកាលពីថ្ងៃទី១៤ ខែវិច្ឆិកា នៅពេលនោះលោក រ៉េន អាយុ៥២ឆ្នាំ បានស្លាប់នៅផ្ទះរបស់គាត់ក្នុងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ បន្ទាប់ពីបានផឹកស្រាសដែលបិតក្នុងមូលដ្ឋាន។ មនុស្សប្រាំនាក់ទៀតបានស្លាប់ចន្លោះពេលនោះ និងថ្ងៃទី២២ ខែវិច្ឆិកា រួមទាំងប្រពន្ធរបស់អ្នកបិតស្រាម្នាក់ផង។

លោក អេង ចំណាត សមាជិកក្រុមប្រឹក្សាឃុំបានមានប្រសាសន៍ថា ជនរងគ្រោះមានអាការដូចជា ឈឺក្បាល ក្អួតចង្អោរ និងចេះតែថប់ដង្ហើមមួយថ្ងៃបន្ទាប់ពីផឹកស្រារួច។ លោកបានមានប្រសាសន៍ថា "មុនពេលពួកគេស្លាប់ជនរងគ្រោះទាំងអស់សុទ្ធតែមានសុខភាពល្អ។ យើងសន្និដ្ឋានថា ពួកគេស្លាប់ដោយសារផឹកស្រាសនេះឯង ប៉ុន្តែយើងមិនទាន់ប្រាកដនៅឡើយទេ ពីព្រោះមិនមានអ្វីកើតឡើងឡើយនៅពេលពួកគេផឹកស្រាពីមុនមក"។

លោក ឆេង ហុង ប្រធានមន្ទីរពេទ្យបង្អែកខេត្តក្រចេះបានមានប្រសាសន៍ថា មន្ត្រីមួយក្រុមមកពីមន្ទីរសុខាភិបាលខេត្តបានទៅកន្លែងនោះកាលពីសប្តាហ៍មុន ដើម្បីធ្វើតេស្តស្រាសនោះ។ លោកបានបន្ថែមថា ទោះយ៉ាងណាយើងមិនអាចឆ្លើយសំណួរណាមួយបានឡើយ ពីព្រោះលទ្ធផលនៃការធ្វើតេស្តមិនទាន់ដឹងនៅឡើយ"។

លោក អ៊ុំ ភី ស្នងការរងនគរបាលខេត្តបានមានប្រសាសន៍ថា លោកបានបញ្ជាឱ្យអ្នកបិតស្រាស និងអ្នកលក់ស្រាសនៅក្នុងតំបន់នោះបិទអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្នសិន បន្ទាប់ពីមានការសង្ស័យអំពីស្រានេះដែលបានលើកឡើងកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ពីរថ្ងៃបន្ទាប់ពីជនរងគ្រោះទី១បានស្លាប់។

លោកបានមានប្រសាសន៍ថា "យើងមិនដឹងថា តើនរណាម្នាក់មានបំណងយកថ្នាំសម្លាប់សត្វល្អិតលាយក្នុងស្រាសនោះឡើយ ប៉ុន្តែយើងនឹងចាប់ខ្លួន ហើយបិទហាងរបស់ពួកគេប្រសិនបើលទ្ធផលបង្ហាញថា មានជាតិពុលក្នុងស្រាមែន"។

លោក អ៊ុំ ភី បានបន្ថែមថា អ្នកភូមិក៏ត្រូវបានដាស់តឿនកុំឱ្យផឹកស្រាសទៀត លុះណាតែមន្ត្រីសុខាភិបាលធ្វើការវាយតម្លៃរួចរាល់សិន។

ការផឹកស្រាសដែលសង្ស័យថាមានជាតិពុលមិនមែនជារឿងប្លែកទេនៅក្នុងប្រទេសកម្ពុជា
រ ទ
ដែលអ្នកភូមិជាច្រើនគ្រួសារបិតនិងលក់ស្រាទាំងនេះ។

កាលពីឆ្នាំ២០១១មនុស្សយ៉ាងតិចប្រាំបួននាក់បានស្លាប់ និងជាច្រើននាក់ទៀតបានធ្លាក់ខ្លួនឈឺនៅក្នុងភូមិដាច់ស្រយាលមួយក្នុងខេត្តពោធិ៍សាត់ បន្ទាប់ពីផឹកស្រាដែលគេសង្ស័យថា មានលាយសារធាតុមេតាណុល៕ **សារុន**

## Local Rice Wine Suspected in Deaths of Six Kratie Villagers

**BY BEN SOKHEAN | NOVEMBER 25, 2014**

Six people have died in a village in Kratie province over the past two weeks after drinking rice wine that local authorities suspect was contaminated with a toxic substance, officials said Monday.

The first death came on November 14, when Or Ren, 52, passed away at his home in Prek Prasap district's Tamao commune after drinking locally made rice wine. Five more people died between then and November 22, including the wife of one distiller.

Commune councilor Eng Chamnat said the victims described symptoms including headaches, vomiting and a sensation of suffocation the day after drinking the suspect home brew.

"Before they died, the victims were all in good health," he said. "We deduce that they died because of the wine, but we are not sure, because nothing happened when they drank the wine before."

Chheng Hong, director of the Kratie referral hospital, said a group of officials from the provincial health department visited his facility last week to test the rice wine.

"However, we cannot answer any questions because the results of their tests have not yet been released," he added.

Deputy provincial police chief Um Phy said he had ordered all rice wine distillers and vendors in the area to temporarily close their businesses after suspicions about the alcohol were raised on November 16, two days after the first victim died.

"We do not know if anyone purposely poisoned the wine with pesticides, but we will arrest them and close their shops if the results for poison are positive," he said.

Mr. Phy added that villagers had also been warned not to accept any more rice wine until the health officials completed their assessment.

The consumption of poisoned rice wine is not uncommon in Cambodia, where many families make and sell their own batches.

In 2011, at least nine people died and dozens more fell ill in a remote village in Pursat province after drinking what turned out to be water mixed with pure methanol, a deadly poison commonly used as an industrial solvent.

## តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា អនុម័តថវិកាជាតិ ៣.៨ពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៥

**ដោយ គុច ណារ៉ែន** | NOVEMBER 29, 2014

កាលពីថ្ងៃសុក្រ រដ្ឋសភាបានអនុម័តថវិកាជាតិចំនួន៣ពួ៨ពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៥ ទោះបីជាក្រុមតំណាងរាស្ត្រគណបក្សប្រឆាំងបានរិះគន់សេចក្តីព្រាងថវិកានេះយ៉ាងខ្លាំងថា ខ្វះសេចក្តីលម្អិត និងមិនបានបោះឆ្នោតក្តី។

កាលពីពេលព្រឹក គណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានធ្វើការបោះឆ្នោតដើម្បីលើកយកសេចក្តីព្រាងច្បាប់នេះមកពិភាក្សាដេញដោលដោយតំណាងរាស្ត្រចំនួន៦៥រូបបានបោះឆ្នោតគាំទ្រ ចំណែកឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន៤៧រូបមិនបានបោះឆ្នោតនោះទេ។ នៅចុងបញ្ចប់នៃការពិភាក្សាដេញដោលពេញមួយថ្ងៃនេះ តំណាងរាស្ត្រគណបក្សប្រឆាំងដែលមានវត្តមាននៅក្នុងរដ្ឋសភា នៅសល់តែ១៩រូបប៉ុណ្ណោះ នៅពេលគណបក្សកាន់អំណាចបោះឆ្នោតអនុម័តថវិកានេះនៅវេលាម៉ោង៦ល្ងាច។

ថវិកាជាតិឆ្នាំ២០១៥ ដែលបានរាប់បញ្ចូលការចំណាយ៤០០លានដុល្លារបន្ថែមពីលើឆ្នាំ២០១៤ និងដែលបានលៃទុកថវិកាភាគច្រើនសម្រាប់វិស័យការពារជាតិ សន្តិសុខ និងអប់រំនេះ មិនបានផ្តល់ការវិភាគលម្អិតថា តើត្រូវចំណាយថវិកាទាំងនោះដោយរបៀបណាឡើយ។

លោក យឹម សុវណ្ណ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងជាអ្នកនាំពាក្យគណបក្សនេះបានមានប្រសាសន៍ថា គណបក្សរបស់លោកមិនបានចូលរួមបោះឆ្នោតទេ ពីព្រោះសេចក្តីព្រាងថវិកានេះមាន "ចន្លោះប្រហោងច្រើន" ពាក់ព័ន្ធនឹងចំណូលចំណាយ។ **តទៅទំព័រទី ១៥**

## CPP Lawmakers Push Through $3.8 Billion National Budget

**BY KUCH NAREN | NOVEMBER 29, 2014**

The National Assembly on Friday approved the $3.8 billion budget for 2015, despite opposition lawmakers, who have slammed the draft budget for its lack of details, abstaining from the vote.

In the morning, the ruling CPP voted to bring the draft bill to a debate, with 65 of its parliamentarians voting in favor while 47 CNRP lawmakers abstained from the vote. By the end of the daylong debate, just 19 opposition members remained in the assembly chamber when the ruling party voted to approve the budget at 6 p.m.

The draft 2015 budget, which included $400 million more in spending than in 2014 and allocated the most money to defense, security and education, did not provide specific breakdowns for how the funds will be spent.

CNRP lawmaker Yim Sovann, a spokesman for the opposition, said his party abstained from the vote because the draft budget contained "a lot of loopholes" in terms of revenue and spending.

"Usually to approve an important draft law for development of the nation, at least a few months are required in order to conduct a thorough study into revenues that are collected by the state and collected from all means of sources through taxation, as well as the spending by sectors [to ensure] the right way and effectiveness," he said during the Assembly session.

Contacted by telephone, Mr. Sovann **Continued to page 17**

តមកពីទំព័រទី ០៤

## ដំណើរពីអាមេរិកទៅអាស៊ី







នៅហុងកុងសម្បូរទេសចរធ្វើដំណើរដោយមានអ្នកដឹកនាំទៅជាមួយកាន់ទង់ជ័យពណ៌ក្រហមនាំមុខភ្ញៀវកាន់ទាំងលិខិតឆ្លងដែនជូនភ្ញៀវទៀតនេះជាសញ្ញានៃការលំបាកក្នុងការធ្វើដំណើរឆ្លងប្រទេសដោយខ្វះការទទួលភ្ញៀវឱ្យបានគ្រប់គ្រាន់ ។ តែយ៉ាងមេចក៏ដោយអីវ៉ាន់ក្នុងយន្តហោះជើងមុនក៏បានចេញចោលយើងផុតទៅហើយទៀតដែរ ។

ម៉ោង១២អាធ្រាតនៃថ្ងៃ១៣ យើងបានមកដល់បាងកកដូចប្រាថ្នាបន្ទាប់ពីជិះយន្តហោះកាថេថ្មីមួយទៀតតែតូចជាងមុនយើងអង្គុយកន្លែងបែកគ្នាអស់រយ:ពេល២ម៉ោងកន្លះ ទើបមកដល់ចំណតយន្តហោះអន្តរជាតិថ្មីស្រឡាងនៃបាងកកដែលមានមនុស្សទទួលភ្ញៀវចេះរាកទាក់រីករាយធ្វើឱ្យយើងមានកម្លាំងនឹងបន្តដំណើរទោះជាហត់នឿយណាស់ក៏ដោយជាពិសេស ប៊ុណ្ណារ៉ូ នៅតែបន្តទាមទារជួយរុញឥវ៉ាន់ដ៏ធ្ងន់ឱ្យយើងដោយទារថា I'll do it ! I'll do it !

## ២យប់៣ថ្ងៃនៅបាងកក

ខានមកកាន់ប្រទេសថៃជាង១០ឆ្នាំ ទេសភាពមិនផ្លាស់ប្តូរប៉ុន្មានទេតែទិដ្ឋភាពនៃការគ្រប់គ្រងបានប្តូរជាស្រស់បស់ដោយភាពទទួលភ្ញៀវស្នាមញញឹមខុសពីអតីតកាលដែលប៉ូលីសអន្តោប្រវេសន៍ថៃមុខដូចយក្ខពេលឆ្លងកាត់ពួកគេម្តងៗអ្នកដំណើររងចាំបោះត្រា "វីសារ" ដូចមកសុំទានអីចឹង។ ទីបញ្ចប់យើងរកឥវ៉ាន់ដែលមកជើងមុនឃើញទាំងអស់ ហើយក៏រក ទូត អ្នកជូនដំណើរដែលមិនដែលឃើញគ្នាពីមុនមកឃើញទៀត ។

ទូត បាននាំយើងទាំង៣ មកដល់សណ្ឋាគារវិនស័រស្វីត Winsor Suite ប្រកបដោយសុវត្ថិ-ភាពថែមទាំងទៅទិញម្ហូបខ្ចប់ឱ្យយើងស្រស់ស្រូបកុំឱ្យឃ្លាន ពីព្រោះពោះកាន់តែកូររៀងៗខ្លួនហើយប៉ុន្តែ ប៊ុណ្ណារ៉ូ បានដេកលក់យ៉ាងស្កប់ស្កល់ទៅហើយដែរ...រីឯសកម្មភាពរាត្រីនឹងក្នុងទីងងឹតនាជុំវិញសណ្ឋាគារនឹងផ្លូវស៊ូគុមវិដ នាវេលាម៉ោង២អាធ្រាត មានភាពត្រឹកត្រេងគួរឱ្យភ្ញាក់ផ្អើលស្រីស្នៀកសំពត់អាវស្តើងខ្លីដើរប្រកៀកគ្នាត្រសងទាំងគូរទាំងក្រុមយ៉ាងរីករាយតែយើងបែរជាសង្វេគនឹងភាពរីករាយនេះទៅវិញដោយសារមើលឃើញពីក្រោយឆាកល្ខោននេះនូវសកម្មភាពពេស្យាចារ្យនឹងភាពខ្វះការងារត្រឹមត្រូវរបស់ស្ត្រីទើបបានជាយើងសង្វេគទៅវិញគួរឱ្យស្តាយ ។ យប់នេះយើងស្រស់ស្រូបបន្តិចបន្តួចហើយសំអាតខ្លួនរួចផ្តួលខ្លួនព្រួសលើគ្រែពូកដ៏វែងបន្ទប់នៅមានក្លិនផ្សរតិចៗ ដែល សូបិន នៅមានចាប់អារម្មណ៍នៅឡើយចំណែកខ្ញុំបានលង់លក់យ៉ាងជ្រៅទៅហើយ ។

ព្រឹកឡើងយើងដាស់គ្នានៅម៉ោង១០ព្រឹកកុំឱ្យដេកយូរពេកវាអាចនឹងខូចដំណេកនារាត្រីបន្ទាប់តែទម្រាំយើងចេញរួចម៉ោង១២ថ្ងៃត្រង់ទៅហើយ យើងក៏សម្រេចហូបអាហារថ្ងៃត្រង់នៅក្បែរៗសណ្ឋាគារដែលទិដ្ឋភាពរាត្រីថ្ងៃសៅរ៍មុននេះបន្តិចបានរលាយស្ងប់ស្ងាត់អស់រលីងដូចស្រមៃមាននៅសល់តែសកម្មភាពទទួលភ្ញៀវទេសចរតែប៉ុណ្ណោះ។ សូបិន និង ប៊ុណ្ណារ៉ូ មិនដែលមកស្គាល់ប្រទេសថៃទេ ជាពិសេស សូបិន បានបែកចេញពីវៀតណាមទៅរស់នៅស.រ.អា.ចំនួន១៥ឆ្នាំហើយ មិនមានសល់អនុស្សាវរីយ៍នៃជីវភាពរស់នៅជនជាតិអាស៊ីច្រើនទេ ម្លោះហើយមានការខ្លាចនឹងផ្សងព្រេងជាមួយម្ហូបតាមផ្លូវណាស់តែខ្ញុំបានពន្យល់ថា គឺម្ហូបនៅតាមថ្នល់នោះ ហើយដែលជាអាហារពិតប្រាកដនៃអ្នកដែលរស់នៅទីនេះតែចុងបញ្ចប់យើងសម្រេចហូបភីហ្សា Pizza នាហាងជាប់គ្នានោះ ដើម្បីបំពេញចិត្ត ប៊ុណ្ណារ៉ូ ដែលបានខំប្រឹងរក្សាខ្លួនជាក្មេងល្អ Good boy តាំងតែពីពេលចេញដំណើរមក ។ យើងបានបញ្ជាភីហ្សា ដែល ប៊ុណ្ណារ៉ូ ចង្អុលក្នុងរូបគឺ ប៊្លូឈីស Blue Cheese តែគេនិយាយថា ចង់ហូបប៉ាប៉ារ៉ូនី Paparroni តែដល់យកម្ហូបមកគេហូបមិនបានដោយប៊្លូឈីសវាធំក្លិនស្អុយបន្តិចលើកនេះយើងបញ្ជាឱ្យយកប៉ាប៉ារ៉ូនីវិញម្តងបន្តិចមកយើងបានទទួលតែចានទទេ២មក ដោយមិនដឹងជាហេតុអ្វី...អស់សង្ឃឹមថា និយាយគ្នាស្តាប់បាន ប៊ុណ្ណារ៉ូ ក៏ហូបតែនំប៉ុងក្រៀមៗដែលនៅជុំវិញភីហ្សាហើយក៏ទាចេញទៅរកហូបអ្វីផ្សេងវិញម្តង។ ចុងបញ្ចប់យើងត្រឡប់មករកម្ហូបនៅសណ្ឋាគារដដែលដោយបញ្ជាម្ហូបដំឡូងនិងត្រីចៀន Fish & French frite ឱ្យកូនទើបរួចខ្លួនឯងយើងចាស់ៗស្រស់ស្រូបតែបន្តិច ក៏ឆ្អែតទៅហើយ ។

រសៀលនេះយើងចង់ទៅឃើញផ្សារបណ្តែតទឹកដ៏ល្បីល្បាញនៅថៃ ទូត បាននិយាយប្រាប់យើងថា ផ្សារទឹកមិនមានទេ នៅពេលល្ងាចតែនៅមានផ្សារទឹកមួយទៀតដែលខ្ញុំស្គាល់គេបើកពេលល្ងាច ។ ទៅទីនោះ យើងជិះឡាន១ម៉ោងកន្លះ ទៅកាន់ខេត្តរាជ្យសីមាទើបដល់ ។ ភ្លៀងធំបានបង្អូរខ្ញោកៗកាត់ដំណើរបស់យើងនៅពេលទៅដល់យប់ក៏មកដល់ដែរតែមនុស្សម្នានៅច្រើនណែនណាន់តាន់តាប់នៅឡើយរថយន្តរាប់រយពាន់រកកន្លែងសំចតស្ទើរមិនបានយើងត្រូវទិញឆ័ត្រ២នឹងអាវភ្លៀងសម្រាប់ ប៊ូណ្ណារ៉ូ នៅពេលត្រូវដើរពីកន្លែងចតឡានទៅកាន់ផ្សារទឹកប៉ិផ្លិចប៉ិផ្លាចពេញផ្លូវ ប៊ុណ្ណារ៉ូ រអ៊ូថា ខ្ញុំឥតចង់ដើរកាត់ផុក ទេកខ្វក់ណាស់ I don't want to walk in the mud ! Ewe ! ដើរកាត់ផ្សារផង រអ៊ូផង ភ្លៀងនៅតែស្រក់មនុស្សនៅតែណែនតែម្តងបន្តិចទទួលថា នេះជាជីវិតអ្នកស្រុកនេះគេរស់នៅយ៉ាងដូចនេះហើយបន្តិចមកក៏ដើរដល់អូរដ៏ចង្អៀតមួយដែលទូកអ្នកលក់ដូរម្ហូប ឬផ្លែឈើ ឬចាំដឹកអ្នកដំណើរនៅពាក់ពពូនគ្នាតាមដងអូរជាភាពអស្ចារ្យមួយដែលមិនដែលប្រទះ។ នៅតាមផ្លូវទៅដងអូរនៃតំបន់អំផាវ៉ាផ្សារអណ្តែតទឹកមានម្ហូបចំណីជ្រក់មាំុនុំនែកកាពិឃីហ៊ីអាំងគ្រប់ប្រភេទដាក់លក់ជាស្នាដៃធ្វើម្ហូបប្លែកៗគ្នាចង់ស្រក់ទឹកមាត់។ ក្លិនឈ្ងុយលាយនឹងផ្សែងសាច់អាំងនានាដឹងថាប្រាកដជាឆ្ងាញ់ណាស់ តែ ប៊ុណ្ណារ៉ូ វាដើរខ្ទប់ច្រមុះឧទានថា Ew ! Stinky !ស្អុយណាស់ៗ ធ្វើឱ្យយើងទប់សំណើចមិនបានសំណាងដែរដែលមិនមាននរណាស្តាប់គេបាន។ យើងបានម៉ៅកាណូតទូកធំស្អាតមួយជិះតែដល់ពេលឡើងម្ចាស់ទូកចង្អុលទូកតូចកញ្ចាស់មួយនៅបាំងពីក្រោយឱ្យយើងទៅជិះទូកនោះវិញគេថាទូកធំនេះឥតចេញទៅទេលុយចេញទៅបាត់ហើយគ្មានជម្រើសក៏សុខចិត្តយកទូកនោះទៅ។ យើងបានប្រទះអូរជាដៃទន្លេដ៏មានប្រយោជន៍ដោយសារកាណូតនាំភ្ញៀវទៅបំពេញភាជនីយដ្ឋានដែលនៅតាមដងទន្លេនឹងដងអូរអ្នកស្រែចំការអ្នករកស៊ីតូចតាចអាចបង្កើតមុខរបរមួយបានជាមួយនឹងអតិថិជនស្រេកឃ្លានមុខម្ហូបថ្មីៗ ឬក៏អាចបំរើតុលាងចានជញ្ជូនឥវ៉ាន់ធ្វើឱ្យមនុស្សជាច្រើនមានការធ្វើដោយមិនចាំច់ទៅសុំទានដូច្នេះពលរដ្ឋបង្កើតការងាររាប់ពាន់ម៉ឺនចិញ្ចឹមខ្លួនដោយខ្លួនឯងបានយ៉ាងប្រសើរ ។ ភ្លៀងរាំងមេឃបានស្រឡះមកវិញតែយប់ក៏កាន់តែចូលមកជ្រៅយើងរៀបខ្លួនត្រឡប់មកបាងកកវិញទាំងមិនទាន់ហូបអាហារល្ងាចនៅឡើយដូច្នេះចាំហូបពេលមកដល់បាងកកសិន។ យើងបានចូលទៅភោជនីយដ្ឋានកណ្តាលវាលមួយដែលប្រជុំដោយអ្នកជំនាញធ្វើម្ហូបថៃសម្រាប់ពលរដ្ឋធម្មតាខ្ញុំបារម្ភតែ សូបិន មិនអាចហូបអាហារទាំងនោះបានដោយសុខភាពមិនមាំទាំយើងបានហៅម្ហូបប្រជាប្រិយ៣-៤ មុខ ។

មានសម្លរម្ជូរតុំយ៉ាំត្រីអាំងឆាបន្លែជាមួយបាយលីង ថ្វីត្បិតតែស្លាបព្រាចានលាងមិនសូវស្អាតតម្រូវឱ្យយើងសំអាតដោយខ្លួនឯងបន្ថែមតែម្ហូបទាំងនោះត្រូវប៉ាន់ សូបិន បានហូបឆ្ងាញ់សរសើរមិនដាច់មាត់ ជាពិសេសកោតសរសើរដល់របៀបរកស៊ីដែលនៅទីវាលប្រក់ដំបូលតែគ្មានជញ្ជាំងដ៏ធំដាក់តុបានប្រហែល១០០ភ្ញៀវចូលពេញអ្នកបំរើឆ្វាត់ឆ្វែងចុងភៅធ្វើម្ហូបតម្រៀបគ្នាជាជួរធ្វើម្ហូបជំនាញខុសៗគ្នាតែបំរើភ្ញៀវបានរហ័សទាន់ចិត្ត ហើយបានឆ្ងាញ់ថែមទៀតជាការដែលមិនសូវជួបប្រទះ។

ស្អែកឡើងជាថ្ងៃដែលត្រូវចេញដំណើរពីបាងកកទៅភ្នំពេញវេលាម៉ោង៥ល្ងាច យើងត្រូវរៀបវ៉ាលីសពីព្រលឹមចេញដើរមើលទីក្រុងជាចុងបញ្ចប់ហើយទៅប្រលានយន្តហោះតែម្តង។ ដោយថ្ងៃនេះជាថ្ងៃអាទិត្យទូតក៏យកភរិយាមកជូនដំណើរយើងដែរ ពីព្រោះជាថ្ងៃបិទហាងយើងមានបំណងទៅទស្សនាវិហារព្រះកែវមរកដនឹងព្រះបរមរាជវាំងថៃតែរកកន្លែងចតឡានមិនបានដោយមនុស្សច្រើនពេកចុងបញ្ចប់យើងរកបានកន្លែងមួយយ៉ាងលំបាកហើយពេលបាយថ្ងៃត្រង់ក៏កន្លងបន្តិចទៅហើយដែរ។

យើងបានរកឃើញភោជនាហារបែរទៅមាត់ទន្លេចៅប្រាយ៉ាយ៉ាងស្អាតច្រឡឹងមួយឈ្មោះ... ។ ដែលមានចំណតកាណូតដឹកអ្នកដំណើរនៅពីមុខម្ខាងនឹងមុខម្ខាងទៀតមានអ្នកដើររកទិញរបស់ប្រើប្រាស់ ឬអនុស្សាវរីយ៍យ៉ាងអ៊ូអរតាមផ្លូវនាក្បែរវាំង។ យើងបានហូបម្ហូបចំណីប្លែកៗហើយឆ្ងាញ់ តទៅទំព័រទី១៦

Continued from Page 12

## Hun Sen, Rainsy Settle Differences in Reform Deal

had rejected a previous proposal by the CNRP to establish a shadow government similar to that of the British parliamentary system.

"The CPP rejected the…idea of the shadow parliament, this would be the British system, but the prime minister himself didn't want hear about the shadow cabinet," he said. "So instead we turned to the American system, where there is a minority leader."

"So we now have this role of the opposition being recognized and the minority leader, who will be the dialogue partner of the prime minister," Mr. Rainsy said, adding that he and Mr. Hun Sen would speak as near equals "on issues of national interest."

Asked why the CNRP had capitulated to a number of the CPP's demands since talks began following the July 22 deal-which said that the current CPP-dominated NEC would remain in place if a new one was not created-Mr. Rainsy said that was the nature of negotiations.

"I think originally the CPP expected more concessions from us, and we also expected more concessions from the CPP," he said. "But finally we went half way, each of us got 50 percent of what we would like to have."

## តមកពីទំព័រទី ១២ លោក ហ៊ុន សែន និងលោក សម រង្ស៊ី ដោះ...

ទុកចោលមិនប្រើប្រាស់នេះបើយោងតាមលិខិតមួយចុះកាលបរិច្ឆេទថ្ងៃព្រហស្បតិ៍របស់លោក ខៀវ កាញារីទ្ធ ដែលបានចេញផ្សាយកាលពីថ្ងៃសុក្រ។

លិខិតនោះមានខ្លឹមសារដូច្នេះថា "ក្រុមហ៊ុន ខេមបូឌា អ៊ិនឌីផេនដេន មេឌា ខូអិលធីឌី ត្រូវមកដាក់នៅក្រសួងព័ត៌មានដើម្បីសុំអាជ្ញាប័ណ្ណដំណើរការស្ថានីយទូរទស្សន៍នៅក្នុងរាជធានីភ្នំពេញ និងការផ្សាយបន្តនៅតាមបណ្តាខេត្ត"។

លោក សម រង្ស៊ី បានមានប្រសាសន៍កាលពីថ្ងៃសុក្រថា លោក ហ៊ុន សែន បានទូរស័ព្ទទៅលោកកាលពីយប់ថ្ងៃព្រហស្បតិ៍ ដើម្បីជម្រាបលោកថា ការទទួចរបស់ក្រសួងព័ត៌មានដែលឱ្យគណបក្សប្រឆាំងចាប់ផ្តើមដំណើរការស្ថានីយទូរទស្សន៍ប្រព័ន្ធឌីជីថលមិនមែនអាណាឡូកនោះ គឺជាការបំពានកិច្ចព្រមព្រៀងថ្ងៃ២២កក្កដា។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "កាលពីយប់មិញនៅពេលពាក់កណ្តាលអធ្រាត្រ លោក ហ៊ុន សែន បានទូរស័ព្ទមកខ្ញុំ ហើយនិយាយថា លោកទទួលស្គាល់ថា វាមិនត្រឹមត្រូវ ហើយថា រដ្ឋាភិបាលនឹងស្វែងរកវិធីសម្រាប់ឯកឧត្តមដំណើរការស្ថានីយទូរទស្សន៍អាណាឡូកដែលឯកឧត្តមអាចដំណើរការបាននៅពេលនេះ"។

ជាផ្នែកមួយនៃកិច្ចព្រមព្រៀងកាលពីម្សិលមិញដែរ លោក ហ៊ុន សែន បានយល់ព្រមទទួលស្គាល់លោក សម រង្ស៊ី ជាផ្លូវការជា "ប្រធានក្រុមភាគតិច" នៅក្នុងរដ្ឋសភាជាតំណែងមួយដែលមេដឹកនាំគណបក្សប្រឆាំងរូបនេះមានប្រសាសន៍ថា "គ្រាន់តែជាតំណែងកិត្តិយស ប៉ុន្តែយ៉ាងហោចណាស់ក៏វាជានិមិត្តរូបដែរ"។

លោក សម រង្ស៊ី បានលើកឡើងថា លោក ហ៊ុន សែន ធ្លាប់បានច្រានចោលសំណើរបស់គណបក្សសង្គ្រោះជាតិដែលសុំបង្កើតរដ្ឋាភិបាលស្រមោលមួយដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងរដ្ឋាភិបាលស្រមោលនៅក្នុងប្រព័ន្ធសភារបស់ប្រទេសអង់គ្លេស។

លោកបានមានប្រសាសន៍ទៀតថា "គណបក្សប្រជាជនកម្ពុជា បានច្រានចោលគំនិតសភាស្រមោលដែលជាប្រព័ន្ធរបស់អង់គ្លេស ប៉ុន្តែលោកនាយករដ្ឋមន្ត្រីខ្លួនឯងមិនចង់ឮពាក្យថាគណៈរដ្ឋមន្ត្រីស្រមោលនោះទេ។ ដូច្នេះហើយ យើងក៏បានងាកទៅប្រើប្រព័ន្ធរបស់អាមេរិកវិញ ដែលមានប្រធានក្រុមភាគតិច។ ដូច្នេះពេលនេះយើងមានតំណែងនេះសម្រាប់ឱ្យគេទទួលស្គាល់គណបក្សប្រឆាំង និងប្រធានក្រុមភាគតិចដែលនឹងក្លាយជាដៃគូសន្ទនារបស់នាយករដ្ឋមន្ត្រី"។ លោកបានលើកឡើងបន្តថា លោក និងលោក ហ៊ុន សែន មានសិទ្ធិស្មើគ្នាក្នុងការពិភាក្សាដោះស្រាយ "លើបញ្ហាផលប្រយោជន៍ជាតិ"។

នៅពេលសាកសួរថា ហេតុអ្វីបានជាគណបក្សសង្គ្រោះជាតិយល់ព្រមទទួលយកការទាមទារមួយចំនួនរបស់គណបក្សប្រជាជនកម្ពុជាចាប់តាំងពីការចរចាបានចាប់ផ្តើមក្រោយពីមានកិច្ចព្រមព្រៀងថ្ងៃ២២ កក្កដា ដែលបានបញ្ជាក់ថា គ.ជ.ប. បច្ចុប្បន្នដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជានឹងត្រូវរក្សាទុកឱ្យនៅដដែល ប្រសិនបើមិនអាចបង្កើត គ.ជ.ប.ថ្មី បាននោះ លោក សម រង្ស៊ី បានឆ្លើយថា នោះគឺជាលក្ខណៈនៃការចរចា។

លោកបានមានប្រសាសន៍បន្តថា "ខ្ញុំគិតតាំងពីដើមមកថា គណបក្សប្រជាជនកម្ពុជារំពឹងចង់បានសម្បទានបន្ថែមទៀតពីយើង ហើយយើងក៏រំពឹងចង់បានសម្បទានបន្ថែមទៀតដែរពីគណបក្សប្រជាជនកម្ពុជា។ ប៉ុន្តែនៅទីបំផុតយើងបានដើរដល់ពាក់កណ្តាលផ្លូវ គឺពួកយើងទទួលបាន៥០ភាគរយម្នាក់នូវអ្វីដែលយើងចង់បាន"៕

**សុខុម (រាយការណ៍បន្ថែមដោយ Colin Meyn)**

## តមកពីទំព័រទី ១៣ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា...

លោកបានមានប្រសាសន៍អំឡុងសម័យប្រជុំសភាពេញអង្គថា "ជាធម្មតា ដើម្បីអនុម័តសេចក្តីព្រាងច្បាប់ដ៏មានសារៈសំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេសយ៉ាងហោចណាស់ក៏ត្រូវការពេលពីរបីខែដែរ ដើម្បីសិក្សាស៊ីជម្រៅលើចំណូលដែលរដ្ឋប្រមូលបាន និងប្រមូលបានពីគ្រប់ប្រភពទាំងអស់តាមរយៈការយកពន្ធ ព្រមទាំងការចំណាយដោយវិស័យនានាផង ឱ្យដើម្បីធានាបាននូវផ្លូវត្រឹមត្រូវ និងប្រសិទ្ធភាព"។

នៅពេលទាក់ទងតាមទូរស័ព្ទ លោក យឹម សុវណ្ណ បានអះអាងថា រដ្ឋអាចទទួលបានចំណូល១.០០០លានដុល្លារបន្ថែមទៀត ប្រសិនបើរដ្ឋាភិបាលប្រមូលពន្ធមានប្រសិទ្ធភាពជាងនេះ។ លោកមានប្រសាសន៍ថា "វិស័យដែលយើងអាចរកចំណូលបានបន្ថែមទៀត គឺពីក្រុមហ៊ុនកាស៊ីណូ និងជាពិសេសពន្ធលើប្រេងសាំងដែលអាចរកបានចន្លោះពី២០០ទៅ៣០០លានដុល្លារក្នុងមួយឆ្នាំ"។

លោកបានមានប្រសាសន៍បន្តថា គណបក្សប្រឆាំងក៏ចង់ឃើញការបង្កើនការចំណាយលើវិស័យអប់រំ វិស័យសុខាភិបាល និងសេវាសាធារណៈផងដែរ ព្រមទាំងការដំឡើងប្រាក់ខែមន្ត្រីរាជការឱ្យដល់យ៉ាងហោចណាស់២លាន ឬប្រហែល៥០០ដុល្លារក្នុងមួយខែ។

លោកបានលើកឡើងបន្តថា "យើងមានការសោកស្តាយដែលសេចក្តីព្រាងច្បាប់នេះមិនពន្យល់ច្បាស់លាស់អំពីបញ្ជីសារពើភណ្ឌរបស់រដ្ឋដែលផ្តល់ឱកាសឱ្យជនមួយចំនួនធ្វើការដោះដូរលក់ និងជួលអចលនទ្រព្យសាធារណៈរបស់រដ្ឋដោយគ្មានតម្លាភាព និងគណនេយ្យភាព"។

លោក ជាម យៀប តំណាងរាស្ត្រគណបក្សប្រជាជន និងជាប្រធានគណៈកម្មការសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរដ្ឋសភាបានការពារសេចក្តីព្រាងថវិកាឆ្នាំ២០១៥នេះ អំឡុងពេលពិភាក្សាដេញដោល។ លោកបានមានប្រសាសន៍ថា វាជារឿងសំខាន់ពាក់ព័ន្ធនឹងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដើម្បី "ធានាបាននូវការបន្តសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយនិរន្តរភាព ព្រមទាំងដើម្បីធានាស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងបរិបទអតិផរណាទាប និងស្ថិរភាពនៃអត្រាប្តូរប្រាក់ផងដែរ"។

មួយភាគធំនៃថវិកាជាតិនេះ ពោលគឺចំនួន៥៦៧លានដុល្លារ ឬស្មើប្រហែល១៥ភាគរយនៃការចំណាយសរុប នឹងទុកសម្រាប់ក្រសួងការងារជាតិ និងក្រសួងមហាផ្ទៃ។ វិស័យអប់រំនឹងទទួលបាន៤៣៣លានដុល្លារ សម្រាប់ឆ្នាំ២០១៥ ពោលគឺច្រើនជាងឆ្នាំ២០១៤ជិត១០០លានដុល្លារ។

ក្នុងចំណោមថវិកាសរុប គឺមានតែចំនួន២០០លានដុល្លារប៉ុណ្ណោះ ដែលនឹងត្រូវទុកសម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ៕

**សុខុម**




## តមកពីទំព័រទី ១៤ ដំណើរពីអាមេរិកទៅអាស៊ី

រហូតដល់ម៉ោង២រសៀល ទើបចប់ ហើយរៀបចំទៅព្រលានយន្តហោះតែម្តង...តែចំពេលស៊ីយពេលចេញពីភោជនីយដ្ឋានឡានបានត្រូវប៉ូលីសចាក់សោរកង់ជាប់ ពីព្រោះយើងឥតបានឃើញថា ជាកន្លែងហាមឃាត់ ម្លោះហើយទូតបានរត់ការណ៍បង់ពិន័យនឹងហៅនគរបាលមកដោះកង់ចេញដល់ម៉ោង៣ ទើបចប់ការណ៍តែម៉ោងក៏រំកិលឆ្ងាយណាស់ហើយដែរ ។ ទូត បានបោះពួយរថយន្តយ៉ាងអស់សង្ឃឹមសំដៅទៅព្រលានយន្តហោះដែលពេលកំណត់ចេញដំណើរនៅម៉ោង៥:១០នាទី តែយើងបានមកដល់ព្រលានម៉ោង៤:១០នាទីទៅហើយ ការរត់ប្រជែងនឹងម៉ោងកំណត់ចេញដំណើរក៏ផ្តើមឡើងដែរ គឺការបន្តកន្ទុយយកសំបុត្រយន្តហោះការដាក់វ៉ាលីសធំៗបញ្ចូលយន្តហោះការឆ្លងប៉ូលីសអន្តោប្រវេសន៍ការឆ្លងឆែកឆេរសន្តិសុខការរត់ទៅរកច្រកទ្វារដែលនៅសែនឆ្ងាយការរត់មិនអាចលឿនទៅបានដោយសារមានក្មេង... ចុងបញ្ចប់យើងបានឈ្នះម៉ោងចេញដំណើររបស់ "បាងកកអ៊ែរវ៉េ Bangkok Airway" តែត្រឹមមួយសសៃសក់បែកញើសពេញខ្លួនដោយសារប៉ុណ្ណារ៉ូ រត់បានលឿនជាងការប៉ាន់ស្មាន ហើយគេសប្បាយនឹងរុញវ៉ាលីសដ៏ធំតែរអិលស្រួលលេងជាល្បែងផង ជួយភាពស្ពាយឥវ៉ាន់រយីងរយោងរបស់ខ្ញុំឱ្យមានភាពប្រសើរបាន ។

អាវទទឹកជោគដោយញើសពេញខ្លួនតែសប្បាយចិត្តនឹងរត់ទាន់ពេលចេញដំណើរហើយនឹងបានមកដល់ភ្នំពេញនៅ៥០នាទីទៀតនេះ ។

### ស្រុកខ្មែរដែលខ្ញុំខានឃើញ១២ឆ្នាំមកហើយ

យន្តហោះ "បាងកកអ៊ែរវេរ Bangkok Airway" បាននាំយើងមកចុះចតនៅអាកាសយានពោធិនតុង បន្ទាប់ពីហោះហើរចំនួន៥០នាទី



ពីទីក្រុងបាងកកមក ។ យើងបានមកដល់ចំណតយន្តហោះដ៏តូចបំផុតជាងព្រលានយន្តហោះដែលយើងទើបឆ្លងកាត់ទាំងអស់នៃពេលថ្មីៗនេះតែទោះជាយ៉ាងណាក្តី ព្រលានយន្តហោះដ៏តូចនេះបានធ្វើឱ្យខ្ញុំរំភើបញាប់ញ័រដោយសារតែខ្ញុំ ទើបត្រឡប់មកជាន់ដីខ្មែរវិញជាលើកដំបូងបន្ទាប់ពីខកខានមិនបានមកឃើញកម្ពុជាចំនួន១២ឆ្នាំដ៏យូរមកហើយ ។ ចំណែកឯ សូបិន និង ប៉ុណ្ណារ៉ូ មិនដែលស្គាល់ស្រុកខ្មែរម្តងណាទេ ។ មិនមានការប្រែប្រួលច្រើនទេ ដោយសារមិនមានមនុស្សប្រសេចប្រសាចចាំទទួលភ្ញៀវជួយបំពេញក្រដាសស្នាមទិដ្ឋាការដើម្បីកំរៃបន្តិចបន្តួចតែក៏មានបុគ្គលិកស័ក្តិ៣ថ្មីច្រើងម្នាក់យកពីយើងបាន២០០បាតលុយថៃដោយក្តីអាណិត ពីព្រោះគ្នាសុំលុយដើម្បីគុយទាវកាហ្វេ ។

ល្ងាចនេះយើងបានកូនប្រុសម្នាក់ឈ្មោះ វីរចិត្ត ហៅ អាលុច មកទទួលយកទៅដាក់សណ្ឋាគារ វីរចិត្ត បានរៀនចប់មហាវិទ្យាល័យខាងសណ្ឋាគារនៅរដ្ឋហ្វ្លរីដាសហរដ្ឋអាមេរិកធ្វើការបាន២ឆ្នាំ ហើយក៏ត្រឡប់មករស់នៅស្រុកខ្មែរវិញហាក់ដូចជាឃើញអត្ថប្រយោជន៍ជាងនៅសហរដ្ឋអាមេរិក ។ ពេលជិះឡានត្រឡប់មកភ្នំពេញវិញ វីរចិត្ត និយាយថា មន្ត្រីប៉ូលីសអន្តោប្រវេសន៍នៅព្រលានយន្តហោះសុទ្ធតែមាន១ណាស់ជិះឡានថ្មី ហើយថ្ងៃ១មកធ្វើការ ហើយក៏បន្តនិយាយពីស្ថានភាពកន្លែងសំណាក់នៅភ្នំពេញនេះ គេមានសម្រាប់អតិថិជនគ្រប់តម្លៃគ្រប់ចំណង់ចូលចិត្ត។ សូបិន បានជ្រើសបន្ទប់សណ្ឋាគារមួយតាមប្រព័ន្ធអាំងទែណែតដែលឱ្យតម្លៃល្អជាងទៅរកដល់ទីកន្លែងតែម្តង។ សូបិន និយាយថា ខ្លួនបានបោះបង់សណ្ឋាគារជាច្រើនដែលសមរម្យដែរ តែទាស់តែផ្កាឈូកសម្រាប់ងូតទឹកវាតូចពេកច្បាស់ជាងូតទឹកមិនស្រួលទេ...ដល់ឮថា ចោលបន្ទប់ច្រើនរកចេះតែមិនបាន ខ្ញុំក៏សុំមើលរូបមើលហើយក៏ឧទ្ទានប្រាប់ថា រូបនោះពុំមែនជាផ្កាឈូកងូតទឹកទេ គឺជាទុយោបាញ់ទឹកលាងគូថនៅក្បែរបង្គន់ដូចគ្នានៅកន្លែងខ្លះគេមិនដាក់ក្រដាស់កិតឱ្យប្រើទេ ។

ចុងបញ្ចប់យើងសម្រេចយកបន្ទប់នៅសណ្ឋាគារបែបបារាំងមួយនាក្បែរវិទ្យាល័យស៊ីសុវត្ថិដែលផ្តល់អាហារពេលព្រឹកនឹងមានអាងហែលទឹកសម្រាប់ទប់ទល់ធាតុអាកាសក្តៅហែងផង ។

រាជធានីភ្នំពេញពីចំណតយន្តហោះអន្តរជាតិពោធិ៍ចិនតុងដល់ភ្នំពេញមនុស្សម្នាធ្វើចរាចរយ៉ាងខ្វល់ខ្វាញ់តាមដងមហាវិថីមិត្តភាពសូវៀតហើយជាការពិតណាស់ដែលថា ទីក្រុងបានផ្លាស់ប្តូររូបរាងធ្វើឱ្យខ្ញុំមើលមិនស្គាល់មែន។ ផ្ទះធំៗល្អស្អាតខ្ពស់ៗ ដុសបន្តបន្ទាប់គ្នាដែលពី១០ឆ្នាំមុនមិនទាន់មាននៅឡើយទេ ដងវិថីចាក់កៅស៊ូស្អាតភ្លឹង សូម្បីតែផ្លូវតូចក៏ចាក់កៅស៊ូរួចហើយដែរ ។

ស្អែកឡើងយើងទៅបរិភោគម្ហូបនាហាងដ៏ធំមួយនៅអាយនម៉ល **តទៅលេខក្រោយ**

## តមកពីទំព័រទី ០៦ ទស្សនៈសារព័ត៌មានពីថ្ងៃ១វិច្ឆិកា...

ទូរទស្សន៍ឯករាជ្យមួយ។ ទូទស្សន៍ទាំង៩សព្វថ្ងៃជារបស់ គបជ ឬក៏ជារបស់អ្នកនៅជិតនឹងអំណាច។ ក្រុមហ៊ុនមួយឈ្មោះ (ប្រព័ន្ធផ្សព្វផ្សាយខ្មែរឯករាជ្យ) គ្រប់គ្រងដោយក្រុមអ្នកជំនួញខ្មែរនៅបរទេសបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មថ្ងៃ២៤តុលា។ គសជ មិនលូកដៃក្នុងកម្មវិធីផ្សាយនោះទេ ថ្ងៃ២៧តុលា រដ្ឋមន្ត្រីក្រសួងពត៌មានបានបញ្ជាក់ថា មិនមានទូទស្សន៍ (អាណាឡូកឱឱ្យទេ មានតែឌីជីថល) ។

*ថ្ងៃ២៨វិច្ឆិកា ហ៊ុន សែន នឹង សម រង្ស៊ីជួបគ្នាម្តងទៀតរៀបចំកែរតម្រូវការខ្វែងគំនិតគ្នាជាចុងក្រោយ: គឺអគ្គលេខាធិការ គជប នឹងត្រូវតែងតាំងដោយសមាជិករបស់ខ្លួនមិនឱ្យមានសមាជិក គជប ណាម្នាក់មានជាប់សាច់ឈាមជាមួយអ្នកទទួលខុសត្រូវនឹងគណបក្សទាំង២ ទូទស្សន៍អាណាឡូកមួយនឹងប្រគល់ឱ្យបក្សប្រឆាំង ហ៊ុន សែន ទទួលស្គាល់ សម រង្ស៊ីជា(អ្នកដឹកនាំគណបក្សភាគតិច) តែមិនទទួលយកនូវសំណើរបង្កើត (រដ្ឋាភិបាលស្រមោល) ដូចគំរូអង់គ្លេស(ខាបូឌាដេលី១១.២៩.១៤)

ឆ្លើយនឹងសំនួរអ្នកកាសែតថា ហេតុអ្វីបានជា គសជ ចុះចាញ់នឹងសំណើរ គបជ អ្វីច្រើនម្លេះ? សម រង្ស៊ី ឆ្លើយថា នេះគឺជាច្បាប់នៃការចរចារគ្នា គបជ រង់ចាំការយល់ព្រមពីយើង រីឯយើងក៏រង់ចាំការយល់ព្រមហ្នឹងពី គបជ វិញដែរ ម្នាក់ៗបានផល៥០ភាគរយ ដែលយើងចង់បាន។

ថ្ងៃ១០ធ្នូ២០១៤ នរាណារីទ្ធ អាណន្តដាយាត ជាអតីតអគ្គលេខាទ្រង់ រ៉ាណារីទ្ធ នឹងជាមនុស្សជិតស្និតបំផុត បានចែកផ្លូវពីទ្រង់តាំងពី២ឆ្នាំមកហើយ អីឡូវបានត្រូវតែងតាំងជា (ទីប្រឹក្សារដ្ឋាភិបាល) ថានះស្មើរដ្ឋមន្ត្រី (ខាមបូឌាដេលី១១.២៤.១៤)។

គបជ មានការលំបាកលំបិននឹងតែងតាំង (អ្នកនាំពាក្យ) របស់បក្ស នេះគឺជាសញ្ញាណនៃការប្រេះឆាផ្ទៃក្នុង (ខាមបូឌាដេលី១១.២៦.១៤)។


# GRAND OPENING

# Friendly Insurance

We serve: Auto, Home, Business owners, Flood Insurance



We do: Tax, Payroll, IRS Audit Representation

We are: License to Practice before the IRS, Enrolled Agent, IRS Certified Acceptance Agent

2 Convenient Locations To Serve You:

LOWELL
42 Branch St
(978)452-3800

LYNN
471 Western Ave
(781)593-4344

Office Hours: Mon- Fri 9 - 6 pm, Sat 9 - 2 pm
Visit us at www.friendlyins.com

# ទស្សនៈអ្នកអាន

**ដោយ : ពុធ សុខសាន្ត**

បន្ទាប់ពីសន្និសីទទីក្រុងប៉ារីស ២៣ តុលា ១៩៩១មក ពលរដ្ឋខ្មែរ យើងមាននិស្សិតបញ្ញាវ័ន្តជាច្រើនចូលរួមធ្វើនយោបាយ ជ្រើសរើសចូលរួមនោះបក្សដែលគួបផ្សំនឹងជួយ ។

តាមការសង្កេតមិនសុទ្ធតែបាតជោគជ័យទេ ដូចជាគណបក្សហ៊្វុនស៊ិនប៉ិចមកពីជាយដែនមានរដ្ឋក្រោះ កាំភ្លើងតូចកាំភ្លើងធំកងទ័ពរាប់ម៉ឺននាក់ ថែមទាំងដឹកនាំដោយត្រកូលស្តេចផែនដី ដែលល្បីឈ្មោះមានការគាំទ្រក្នុង និងក្រៅប្រទេស ឈ្នះឆ្នោតនៅអាណត្តិទី១ លម្មនឹងអាចឈ្នះ បក្សកុម្មុយនីស្តនៅអាណត្តិក្រោយៗមកទៀតបាន ។

តែមិនដូចរាស្ត្ររំពឹងទុកទេ នេះក៏ព្រោះមេដឹកនាំបក្សខ្សោយគំនិតអន់ រហូតសព្វថ្ងៃសឹងថា លែងមានតម្លៃទៀតហើយ ជីវិតនយោបាយគាត់ ។

បោះឆ្នោតអាណត្តិទី២ មានគណបក្សច្រើនប្រធានបក្សច្រើនជាតំណាងរាស្ត្រចេញពីបក្សធំៗ ២ ដែលបក្សកុម្មុយនីស្តវៃបំបែកខ្ទេចខ្ទី ដូចជាលោក ឡយ សីមឈៀង លោក អ៊ឹង ហួត, អៀង ម៉ូលី, លោក ថាច់ រ៉េង, លោក សម រង្ស៊ី, នរោត្តមរណឫទ្ធិ ។ យើងទាំងអស់គ្នាឃើញហើយ ព្រោះតែការបែកបាក់គ្នារបស់អ្នកប្រជាធិបតេយ្យធ្វើឱ្យសន្លឹកឆ្នោតបែកខ្ញែក ឈ្នះទៅគណបក្សប្រជាជនដែលអ្នកប្រកាន់យុត្តិធម៌ស្អប់ខ្ពើម ព្រោះជំនួយបរទេសជួយយ៉ាងច្រើន មិនបានធ្វើឱ្យរាស្ត្រខ្មែរបានធូរធារទេ ។

បោះឆ្នោតអាណត្តិទី២ មានតែគណបក្សអ្នកប្រជាធិបតេយ្យមួយគត់បាន៩៦កៅអី គឺគណបក្ស សម រង្ស៊ី ក្រៅពីនេះរលាយបាត់រូបបន្តិចម្តងៗសូន្យសុងអស់ ។

អស់លោកអ្នកនយោបាយ ដែលជាតំណាងរាស្ត្រនឹងបញ្ញាវ័ន្តខ្លះ ព្រមលក់ខ្លួនឱ្យបក្សប្រជាជន ទើបអតីតអ្នកតំណាងរាស្ត្រទាំងនោះ ដូចជាសម្លាប់ជីវិតនយោបាយខ្លួនដោយខ្លួនឯងផ្ទាល់ សូម្បីខ្លួនជាអ្នកតស៊ូនៅព្រំដែនខ្មែរថៃល្បីថា ស្អប់យួនដល់ឆ្អឹងក្តី ។

តើគួរឱ្យមោទនភាពដែរ ឬទេ ? ឯកឧត្តម សម រង្ស៊ី អាចដើរមកដល់ចំណុចសព្វថ្ងៃនេះបាន គួរឱ្យកោតសរសើរដែរឬទេ? ដែលបក្សកាន់អំណាចរិះរកវិធីគ្រប់បែបយ៉ាង ចង់ឱ្យគាត់ស្លាប់ ចង់ឱ្យគាត់ខ្ទាតចេញពីឆាកនយោបាយ និរទេសជាច្រើនដង ។ មកពីហេតុអ្វីទើបអាណត្តិនេះតំណាងរាស្ត្រទាំងអស់បក្សសង្គ្រោះជាតិមិនមានលក់ខ្លួនទៀតដូចមុនៗ អាចមកពីអ្នកលក់ខ្លួនមុនៗអត់តម្លៃល្បីកំសោយទេដឹង ឬក៏សម័យ Facebook លាតត្រដាងលឿនអាចនិយាយបានថា ធ្វើល្អឃើញល្អ ធ្វើអាក្រក់ឃើញអាក្រក់ភ្លាមៗ ឬក៏ប្រធាន អនុប្រធានបក្សសង្គ្រោះជាតិពិតជាមានសមត្ថភាពពិតប្រាកដអាចជួយស្រោចស្រង់ ប្រទេសជាតិ និងពលរដ្ឋខ្មែរបានទៅថ្ងៃអនាគត ។

តាមការវិភាគនយោបាយនៅប្រទេសកម្ពុជាសព្វថ្ងៃ មានវិធីមួយដែលអាចយកឈ្នះបក្សសង្គ្រោះជាតិបាន គឺប្រើទឹកលុយ ទិញអ្នកស្រលាញ់លុយ ព្រមនឹងឱ្យបក្សកាន់អំណាច ប្រើឱ្យបំផ្លាញប្រទេសជាតិខ្លួនឯង ។

ចុះបើសម័យ Internet Facebook លែងមានអ្វីជាអាថិកំបាំងទៀតទេ! តើនៅមានមនុស្សប៉ុន្មានទៀត ដែលព្រមនឹងធ្វើខ្លួនជាមនុស្សសម្លាប់ជាតិឯង រួមដៃជាមួយសត្រូវសូរពូជ ប្លន់ទឹកដីប្រទេសខ្លួនឱ្យបាត់បង់បន្តិចម្តងៗ ដូចជាព្រមគាំទ្រឱ្យមានការរំលោភសិទ្ធពលរដ្ឋខ្មែរគ្រប់ទិសទីទូទាំងប្រទេស តើនៅមានអ្នកណាទៀត ព្រមឱ្យគេចែកចាយទង្វើអមនុស្សធម៌ឆោតល្ងង់ ព្រោះតែប្រាក់ បុណ្យស័ក្តិ អំណាចតាម Facebook ពេញពិភពលោក ។

បើបានវិភាគឱ្យគ្រប់ជ្រុងជ្រោយ មិនមានហេតុផលសមរម្យណាមួយទេ ដែលតាំងខ្លួនជាអ្នកនយោបាយ ទៅបំផ្លាញគណបក្សសង្គ្រោះជាតិ ហៅថាល្អនោះ ។

សព្វថ្ងៃព័ត៌មានចេញគ្រប់ទិសទីស្មើមាត់ទិព្វភ្នែកទិព្វ ត្រចៀកទិព្វ គ្មានឥទ្ធិពលណាស្មើទឹកប្រាក់ទេ ដែលបំផ្លាញមនសិការមនុស្សទន់ជ្រាយឱ្យអស់តម្លៃ ។

អ្នកអាចរិះគន់គណបក្សសង្គ្រោះជាតិ ថាខុសបែបនេះបែបនោះបាន តែមិនប្រាកដទេថាគេគ្រប់គ្នានឹងយល់ដូចអ្នក ព្រោះសម័យនេះខុសពីសម័យមុន មានតែអ្នកគិតថា យុត្តិធម៌គ្មាននៅក្នុងកម្ពុជាទេ ដែលព្រមយកលុយបំផ្លាញខ្លួនឯងទីបំផុតអ្នកនឹងអាស្សូរខ្លួនឯងហើយ ។

ព្រោះតែភាពក្រីក្រលំបាកវេទនា ក៏មានអ្នកខ្លះធ្វើចោរ ឆបោក ប្រើគ្រឿងញៀន បាត់បង់តម្លៃជាមនុស្ស តែក៏មានពលរដ្ឋខ្មែរខ្លះ ទាំងក្មេងទាំងចាស់ចូលរួមស្តាប់ថ្នាក់ដឹកនាំបក្សសង្គ្រោះជាតិ ដែលផ្តល់ក្តីសង្ឃឹមជាបណ្តើរៗរហូតទៅ ។

## បុណ្យផ្កាសាមគ្គីជួយជនក្រីក្រ

យើងខ្ញុំជាពលរដ្ឋខ្មែរនៅទីក្រុង Lowell, Lynn Lawrence, Springfield ក្នុង រដ្ឋម៉ាសាឈូសេតបានមូលមតិគ្នាជាឯកច្ឆន្ទរៀបចំបុណ្យផ្កាសាមគ្គីមួយ ដើម្បីប្រមូលបច្ច័យទៅចែកជូនជនចាស់ជរា ពិការគ្មានទីពឹងជនក្រីក្រ រើសសម្រាមនៅស្ទឹងមានជ័យ និងបងប្អូនដែលគេដេញចេញពីផ្ទះសម្បែង ដីធ្លី ។

អាស្រ័យហេតុនេះ សូមអញ្ជើញបងប្អូនរួមឈាមខ្មែរទាំងអស់ ចូលរួមចាប់មគ្គផលតាមសទ្ធារជ្រះថ្លា និងទទួលផល្លានិសង្សតាមក្តីប្រាថ្នារៀងៗខ្លួន ។

**កម្មវិធីបុណ្យ**

ថ្ងៃ៨រោច ខែមគសិរ ឆ្នាំមមី ឆស័ក ពុទ្ធស័ករាជ ២៥៥៨ ត្រូវនឹងថ្ងៃអាទិត្យ ទី១៤ ខែធ្នូ គ.ស ២០១៤ ។

ទីកន្លែង ភោជនីយដ្ឋាន សំពៅមាស 454 Chelmstord St.Lowell,MA 01851 Tell: 978-453-2073

ម៉ោង ៨ព្រឹក ជួបជុំគ្នាសូត្រមន្តប្រគេនចង្ហាន់រហូតដល់ម៉ោង១២ថ្ងៃត្រង់

ព័ត៌មានបន្ថែមសូមទាក់ទង : **978-394-3093 ឬ 978-914-1373**

Continued from Page 13

## CPP Lawmakers Push Through....

claimed that an additional $1 billion in revenue could be generated if the government collected taxes more effectively.

"Those areas where we could generate more revenue are from casino operations, and especially tax on gasoline, which could be worth $200 to $300 million annually," he said.

Mr. Sovann said the opposition also wanted to see increased spending on education, health and social services, as well as a boost to civil servants' pay to at least 2 million riel, or about $500, a month.

"We're so sorry that the draft law also does not explain clearly the state's inventory, which gives the chance for some people to do swapping, selling and leasing of state public properties without transparency and accountability," he added.

CPP lawmaker Cheam Yeap, head of the National Assembly's economics and finance commission, defended the draft 2015 budget during the debate.

Mr. Yeap said it was important in terms of public finance policy to "ensure the continued accomplishment of high and sustainable economic growth, as well as to ensure the stability of the economy and finances in the context of low inflation and the stability of the exchange rate."

The largest portion of the budget—$567 million, or about 15 percent of total spending—will go to the ministries of defense and interior. The approved budget allocation of $433 million for education in 2015 is nearly $100 million more than in last year's budget.

Only $200 million of the total budget will be allocated to provincial, district and commune governments.





# ២២- ខេត្ត ឧត្តរមានជ័យ

**ផ្ទៃដី៖** ៦ ១៥៨គម² **ប្រជាជន៖** ១៨៥ ៨១៩ នាក់
**ក្រុងសំរោង៖** ៥១ ៤១៤ នាក់ **ចំនួនស្រុក៖** ៤
**ចំនួនឃុំ-សង្កាត់៖** ១៩ **ចំនួនភូមិ៖** ២២៧
**ដង់ស៊ីតេប្រជាជន**(មនុស្ស/គម²)**៖** ៣០ នាក់




ខេត្តឧត្តរមានជ័យឋិតនៅភាគពាយ័ព្យប្រទេស មានព្រំប្រទល់ខាងជើងជាប់ប្រទេសថៃ (ខេត្តបុរីរាំ-ខេត្តសុរិន-ខេត្តស៊ីសាកេត) ខាងកើតជាប់ខេត្តព្រះវិហារ ខាងត្បូងជាប់ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ។ ប្រទេសកម្ពុជាខ័ណ្ឌចែកដីនឹងប្រទេសថៃដោយជួរភ្នំដងរែកគឺជាព្រំដែនធម្មជាតិមានប្រវែង២២៤គម.(គ្មានដីវាលរាបទេជាមួយប្រទេសថៃគឺសុទ្ធតែភ្នំដោយមានតែច្រក៥សំរាប់ចេញចូលប៉ុណ្ណោះគឺ៖ ច្រកជុបគគី ច្រកថ្មដូន ច្រកអូរស្មាច់ ច្រកជាំសាងាំ និង ច្រកព្រះប្រឡាយ ។ ខេត្តឧត្តរមានជ័យនិងខេត្តព្រះវិហារបង្កើតនៅឆ្នាំ១៩៦០ដោយយកទឹកដីមួយផ្នែកធំពីខេត្តសៀមរាប ។ ខេត្តឧត្តរមានជ័យមានប្រាសាទបុរាណ(នៅមានរូបរាង)១៨កន្លែង ស្ថានបុរាណ៧កន្លែង ទួលប្រាសាទ៨២កន្លែង និងស្រះបុរាណ១៤កន្លែង ។ ប្រាសាទសំខាន់ៗមាន៖ ប្រាសាទព្រហ្មកិល ប្រាសាទតាមន្តធំ ប្រាសាទតាក្របី ប្រាសាទចន្ទ។

រដ្ឋបាល **ខេត្តឧត្តរមានជ័យ** មានស្រុកចំនួន ៤ - ក្រុង **១** - ឃុំ-សង្កាត់ចំនួន **២៤**

**១-ស្រុក អន្លង់វែង** ➤ អន្លង់វែង ត្រពាំងតាវ ត្រពាំងប្រីយ៍ ថ្លាត លំទង (៥ឃុំ)

**២-ស្រុក បន្ទាយអំពិល** ➤ អំពិល បេង គោកខ្ពស់ គោកមន (៤ឃុំ)

**៣-ស្រុក ចុងកាល់** ➤ ជើងទៀន ចុងកាល់ ក្រសាំង ពង្រ (៤ឃុំ)

**៤-ស្រុក ត្រពាំងប្រាសាទ** ➤ បាក់អន្លូង ផ្អាវ អូរស្វាយ ព្រះប្រឡាយ ទំនប់ដាច់ ត្រពាំងប្រាសាទ (៦ឃុំ)

**៥-ក្រុងសំរោង** ➤ បន្សាយរាក់ បុស្បូវ កូនក្រៀល សំរោង អូរស្មាច់ (៥សង្កាត់)


ប្រាសាទតាមន្តធំ


ប្រាសាទតាក្របី


ប្រាសាទចន្ទ

នៅក្នុងរជ្ជកាលព្រះជ័យវរ្ម័នទី៧(១១៨១-១២១៩)មានការសាងសង់ប្រាសាទជាច្រើនដែលរៀបរាប់ពីប្រាសាទសំខាន់ៗឋិតនៅតាម **ផ្លូវបុរាណសម័យអង្គរ** ពីរាជធានីអង្គរទៅភីម៉ៃ ឆ្លងកាត់តាមជួរភ្នំដងរែកខេត្តឧត្តរមានជ័យ ពីរាជធានីអង្គរទៅវត្តភូ ឆ្លងកាត់ខេត្តឧត្តរមានជ័យ ប្រាសាទតាមន្តធំ ប្រាសាទព្រះវិហារ ។ ដោយឡែក**ខេត្តឧត្តរមានជ័យមានប្រាសាទបុរាណ**(នៅមានរូបរាង)១៨កន្លែង ស្ថានបុរាណ៧កន្លែង ទួលប្រាសាទ៨២កន្លែង និងស្រះបុរាណ១៤កន្លែង។ ប្រាសាទសំខាន់ៗនៅខេត្តឧត្តរមានជ័យមានប្រាសាទព្រហ្មកិល **ប្រាសាទតាមន្តធំ ប្រាសាទតាក្របី ប្រាសាទចន្ទ** ជាដើម ។

ប្រជាជនខេត្តឧត្តរមានជ័យប្រើប្រាស់តាំងពីបុរាណរហូតដល់ពេលបច្ចុប្បន្នគឺប្រើប្រាស់ទឹកស្រះជាមូលដ្ឋាន ឯទឹកអណ្តូងមិនអាចហូបបានឡើយដោយមានជាតិកំបោរ ។ សក្តានុពលរបស់ខេត្តអាចមានរ៉ែក្រោមដី (ត្បូងថ្ម រ៉ែមាស និល ថ្មកំបោរ ដែក និងសំណ ជាដើម)។


# ហ្វេយ៍មឹកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
# Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852

**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

***លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។***

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

### ខេត្តឧត្តរមានជ័យបិតនៅតាមជួរភ្នំដងរែក



សណ្ឋានដីប្រទេសកម្ពុជា មាន ទំនាបកណ្តាល ព័ទ្ធជុំវិញដោយភ្នំនិងខ្ពង់រាប គឺភ្នំក្រវាញនៅនិរតី **ភ្នំដងរែកនៅខាងជើង** ខ្ពង់រាបខាងជើង ខ្ពង់រាបខាងកើត និងឦសាន

**ជួរភ្នំដងរែក** : *សណ្តូក ពីខាងកើត ទៅខាងលិច គឺ ពីជ្រលងទន្លេមេគង្គទៅជ្រលងទន្លេចៅជ្រះយ៉ា ឬទន្លេមេណាម នៃ ប្រទេសថៃ ។ តាមពិតដងរែកមិនមែនជាជួរភ្នំទេតែជាតែមខាងត្បូងនៃខ្ពង់រាបនគររាជ (Korat) ដែលស្ថិតក្នុងភូមិភាគខាងកើតនៃប្រទេសថៃ៖ គឺជាជញ្ជាំង ថ្មក្រៃ -ថ្មភក់ (Grès) និងជាមុខចំណោតមួយយ៉ាងវែងបណ្តោយប្រហែល៣០០ គ.ម.និង មានរយៈកំពស់ចុះជាលំដាប់ ពីខាងកើតទៅខាងលិច (គឺពី ៧០០ ម. ទៅ ២០០ ម.) ។ ជួរភ្នំដងរែកមានមុខចំណោតខាងលើខ្ពង់រាបខ្មែរខាងជើង តែមានចំណោតយ៉ាងទេរទាបទៅខាងប្រទេសថៃ ។ ការដែលមានចំណោតសង្ខាងមិនស្មើគ្នាដូច្នេះជាការបញ្ជាក់ឲ្យឃើញថាទំនាបខ្មែរនិងទំនាបថៃមានរយៈកំពស់ខុសគ្នាយ៉ាងសម្បើម គឺពី ៥០ ទៅ ១៥០ ម. នៅប្រទេសខ្មែរ និង ពី ១០០ទៅ ៣០០ ម. នៅប្រទេសថៃ ។ ពី ខាងកើត ទៅខាងលិច កំពូលខ្ពស់ជាងគេមាន ៖*

*ភ្នំដងរែក (៧៥៦ ម.) ជាកំពូលខ្ពស់បំផុត, ភ្នំព្រះវិហារ (៦២៥ ម.),ភ្នំអណ្តូងស្វាយ (៤៥៧ ម.) ភ្នំម៉ាក់កែ (៥៣៧ ម.) ។ នៅចន្លោះ ភ្នំ មានច្រកដែលសម្រួលការទាក់ទងរវាងភូមិភាគថៃខាងកើត និង ទំនាបកណ្តាល នៃ ប្រទេសខ្មែរ ។* ***ច្រកសំខាន់ៗគឺ*** *ច្រកអន្សែ, ច្រកដូនតាប៉ាយ, ច្រកដូនឪ, ច្រកតាព្រហ្ម ច្រកកូន ច្រកជុបគគី ច្រកថ្មដូន ច្រកអូរស្មាច់ ច្រកជាំសាង៉ាំ និងច្រកព្រះប្រឡាយ ។*

*ខ្ពង់រាបខាងជើងជាខ្ពង់រាបប្រកបទៅដោយល្បាប់ចាស់ ឆ្លាស់គ្នានឹងថ្មបាយក្រៀម និង ជាតំបន់ព្រៃរបោះ ។ ខ្ពង់រាបនេះស្ថិតនៅត្រង់ខេត្តបាត់ដំបង, ខេត្តសៀមរាប និង ខេត្តកំពង់ធំ គឺភ្ជាប់ទំនាបកណ្តាលទៅជួរភ្នំដងរែក ។ នៅតាមទ្រនង់កណ្តាល នៃ ខ្ពង់រាបនេះមានកូនភ្នំដាច់ៗពីគ្នា ដូចជា ភ្នំស្វាយចេក, ភ្នំកំបុត, ភ្នំចុងកាល់, ភ្នំត្បែង (៥២៤ ម.), ភ្នំគូលែន (៤៩៦ ម.),ភ្នំរយោង (៤៣៣ ម.) ។ នៅខាងត្បូងខ្សែទ្រនុងនេះ មានជួរភ្នំប្រហាក់ប្រហែលគ្នានឹងភ្នំខាងលើដែរដែលស្ថិតនៅជិតទំនាបកណ្តាល គឺ ភ្នំសន្ទុក (១៨០ ម.) ភ្នំអោង (២៦៨ ម.) និង ភ្នំជី (៦៧៣ ម.) ។*

### លក្ខណៈទូទៅនៃខេត្តឧត្តរមានជ័យ

*ខេត្តឧត្តរមានជ័យបិតនៅភាគពាយ័ព្យប្រទេស មានព្រំប្រទល់ខាងជើងជាប់ប្រទេសថៃ (ខេត្តបុរីរាំ-ខេត្តសុរិន-ខេត្តស៊ីសាកេត) ខាងកើតជាប់ខេត្តព្រះវិហារ ខាងត្បូងជាប់ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ។ ប្រទេសកម្ពុជាខ័ណ្ឌចែកដីនឹងប្រទេសថៃ ដោយជួរភ្នំដងរែក គឺជាព្រំដែនធម្មជាតិមានប្រវែង២២៤គម.(គ្មានដីវាលរាបទេជាមួយប្រទេសថៃគឺសុទ្ធតែភ្នំដោយមានតែច្រក៥សំរាប់ចេញចូលប៉ុណ្ណោះគឺ៖ ច្រកជុបគគី ច្រកថ្មដូន ច្រកអូរស្មាច់ ច្រកជាំសាង៉ាំ និង ច្រកព្រះប្រឡាយ ។ ខេត្តឧត្តរមានជ័យនិងខេត្តព្រះវិហារបង្កើតនៅឆ្នាំ១៩៦០ដោយយកទឹកដីមួយផ្នែកធំពីខេត្តសៀមរាប ។*

***ខេត្តឧត្តរមានជ័យមានអាកាសធាតុក្តៅសើម*** *ដូចនៅទូទាំងប្រទេសកម្ពុជាដែរ ។ រដូវក្តៅចាប់ពីខែមីនាដល់ខែឧសភា (សីតុណ្ហភាពពី២៧ទៅ៣៧អង្សា) រដូវវស្សាចាប់ពីខែឧសភាដល់តុលា (សីតុណ្ហភាពពី២៤ទៅ៣២អង្សា និងសំណើម៩០%) និងរដូវរងារចាប់ពីខែវិច្ឆិកាដល់ខែមីនា (សីតុណ្ហភាពពី២២ទៅ២៨អង្សា) ។*

***តាមការជំរឿនទូទៅប្រជារាស្ត្រឆ្នាំ២០០៨*** *ខេត្តឧត្តរមានជ័យមានប្រជាជន ១៨៥ ៨១៩នាក់ ប្រុសមាន ៩៣ ៦៤៦នាក់ ស្រីមាន ៩២ ១៧៣នាក់ ។ ដង់ស៊ីតេប្រជាជនមាន៣០នាក់*


AccuCare Home Care Agency
Group Adults Foster Care Program

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
To be eligibled for GAFC you must:
- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មាស់ហែលស្តង់ដា (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

**ផលប្រយោជន៍ទទួលបាន :**
Benefits you will get:
- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# មាតាបិតាគួរបង្រៀនកូន ដុសធ្មេញ ទើបត្រឹមត្រូវ



នៅពេលដែលធ្មេញរបស់ទារកចាប់ផ្តើមដុះឡើងដំបូងអ្នកអាចនឹងចាប់ផ្តើមដុសធ្មេញឱ្យទារកបានហើយ ។

អ្នកត្រូវជ្រើសយកច្រាសមួយដែលមានសរសៃទន់ និងក្បាលតូចដែលមានដងកាន់ដៃធំដំបូងអ្នកជាមាតាបិតាគ្រាន់តែផ្សើមច្រាសដុសធ្មេញដើម្បីដុសឱ្យកុមារអាយុ១ឆ្នាំ ។ អ្នកអាចចាប់ផ្តើមដោយប្រើថ្នាំដុសធ្មេញប៉ុនគ្រាប់សណ្តែកដែលគ្មានជាតិភ្លុយអរ៉ាយ ។ រង់ចាំរហូតបានអាយុយ៉ាងតិច២ឆ្នាំ ទើបប្រើថ្នាំ ដែលមានជាតិភ្លុយអរ៉ាយ ។ ដុសថ្នមៗនៅជុំវិញធ្មេញរបស់កុមារខាងមុខ និងខាងក្រោយ ។

ឪពុកម្តាយគួរដុសធ្មេញកូន រហូតដល់ពេលដែលពួកគេមានអាយុគ្រប់គ្រាន់ដែលអាចកាន់ច្រាសដុសខ្លួនឯងបាន ។ ជាពិសេសនោះត្រូវតាមដានការដុសធ្មេញរបស់គេរហូតដល់កុមារអាចលាងជម្រះ និងខ្ពុរសម្អាតមាត់ដោយមិនត្រូវការជំនួយ ។ ប្រសិនបើមានបញ្ហាណាមួយ សូមយកកូនរបស់អ្នកទៅពេទ្យធ្មេញកុមារសម្រាប់ធ្វើការពិនិត្យ ហើយបើទោះបីជាមិនមានបញ្ហាណាមួយក៏ដោយ កូនរបស់អ្នក គួរតែទៅពិនិត្យធ្មេញនៅអាយុ១ឆ្នាំ ទើបជាការប្រសើរ ៕

# បញ្ហានៃការឈានទៅរកភាពថ្លង់របស់កុមារ

ក្នុងនាមជាមាតាបិតាម្នាក់អ្នកត្រូវតែជាមនុស្សទីមួយដែលចាំបាច់ត្រូវកត់សម្គាល់ពីបញ្ហានៅក្នុងការស្តាប់កូនអ្នក ។ ដូច្នេះរោគសញ្ញាមួយចំនួនដែលចង្អុលបង្ហាញពីបញ្ហានេះដូចជា :

- មិនមានប្រតិកម្មទៅនឹងសំឡេងឮខ្លាំង ។
- មិនឆ្លើយតបទៅនឹងសំឡេងរបស់អ្នក ។
- ការហៅជាសំឡេងមួយឱ្យខ្លាំងល្មម ប៉ុន្តែពួកគេហាក់បីដូចជាមិនចង់ឮទៅវិញ ។
- ក្មេងជាមួយនឹងបញ្ហារលាកត្រចៀកក៏អាចមានសញ្ញាផងដែរ :
- កេះ ឬត្រដុសត្រចៀក
- ជានិច្ចកាលឆាប់ខឹងដោយគ្មានហេតុផល
- ជាទូទៅតែងតែព្រងើយកន្តើយ ឬធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់
- មិនយល់ពីទិសដៅ
- មានគ្រុនក្តៅ
- មានការឈឺចាប់ត្រចៀក ៕






# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

## Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



# ANGKOR AUTO SERVICE,INC.

## ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

**Auto Body and Maintenance**



**BODY WORKS**

**Auto glass and windshields**
**Auto Frame Straightening and Painting**

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ីរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

## តមកពីទំព័រទី ០២ ទៅលេងគ្រួសារនៅស្រុកបាយឆៅ...

យើងបាននាំគ្នាទៅមើល"ស្រះគូរ"ដ៏ល្បីល្បាញ

ដោយរឿងព្រេងនិទានថា កាលពីព្រេងនាយស្ត្រីជាអ្នកគ្រប់គ្រងគ្រួសារដែលជាការងារលំបាកលំបិនដោយមានបំណងឱ្យមានការផ្លាស់ប្តូរ ក៏បបួលក្រុមបុរសភ្នាល់គ្នាថា ត្រូវជីកស្រះមួយម្នាក់នាពេលរាត្រីមួយដែលកំណត់ទុក បើនរណាជីកបានស្រះធំជាងក្នុងមួយយប់រហូតដល់ផ្កាយព្រឹករះឡើងនោះ ក្រុមនោះនឹងឈ្នះ រីឯអ្នកចាញ់នឹងទទួលភារកិច្ចគ្រប់គ្រងគ្រួសារជារៀងរហូតតទៅ។ ដោយអំនួតថាខ្លួនមុខជានឹងឈ្នះខាងបុរសក៏យល់ព្រមភ្នាល់។ ដល់ថ្ងៃកំណត់ក្រុមស្ត្រីនឹងក្រុមបុរសប្តេមប្រកួតនាពេលព្រលប់ដោយប្រឹងកាយជីរៀង១ខ្លួនឱ្យកើតជាស្រះម្ខាងម្នាក់តែនារំលងអាធ្រាតទាបភ្លឺខាងក្រុមស្ត្រីធ្វើការបង្ហោះគោមឡើងខ្ពស់ធ្វើឱ្យខាងបុរសច្រឡំថា ផ្កាយព្រឹកបានរះហើយ ក៏នាំគ្នាទៅដេកយ៉ាងនឿយហត់ ចំណែកខាងស្ត្រីនៅបន្តរជីកកាយរហូតដល់ព្រឹក។ ភ្លឺឡើងលទ្ធផលគឺស្រះស្រីបានធំជាងធ្វើឱ្យបុរសភ្នាល់ចាញ់ ហើយទទួលភារៈកិច្ចគ្រប់គ្រងគ្រួសារតាំងពីពេលនោះមក ហើយស្រះមួយគូរនោះ ក៏បានកកើតនាពេលនោះ ហើយមានឈ្មោះថា ស្រះគូររហូតមក។

ស្រះគូរទើបនឹងប្រារព្ធពិធីលយប្រទីបអកអំបុកជូនសហគមន៍ខ្មែរនៅត្រាវិញ កាលពីប៉ុន្មានថ្ងៃមុននេះសោះរោងល្ខោន ឬរោងអកអំបុកនៅមិនទាន់រុះរើចេញនៅឡើយ តែនៅតែមានទេសចរខ្មែរមកដើរលេងច្រើនក្រោមម្លប់ដើមឈើទាលអាយុរយឆ្នាំនៅឡើយ ពីព្រោះមានសារមន្ទីរប្រវត្តអម្បូរខ្មែរដ៏ធំទូលាយមួយនៅក្បែរនោះផង។ អ្នកលក់ដូរនៅជុំវិញបរិវេណនិយាយអំពីវត្ថុអច្ឆរិយៈ នៃខ្មុមអ្នកតា នៅទីនោះនឹងការប៉ុនប៉ងលុបស្រះស្រីចោលតែមិនបានសម្រេច ក៏រៀបចំជួសជុលឡើងទៅវិញផង។


នៅលេងវត្តកំពុងនិគ្រោធដែលមានព្រះសង្ឃ៧០ជាជាងម្នាក់

នាអម្លុងពេលដែលយើងស្នាក់អាស្រ័យនៅបាយឆៅ យើងចូលចិត្តហូបគុយទាវពេលព្រឹកដ៏ឈ្ងុយឆ្ងាញ់ទិញពីទៀមមួយនៃទីផ្សារដីហុយដែលម៉ែទៅទិញទុកឱ្យតាំងពីព្រលឹមស្រាង១ក្រោយមកគាត់ទិញបបរពោតនឹងនុំនែកប្លែក១ច្រើនមុខទៀត ដូចជាសូយ នុំបាញ់ឌុក ដែលដូចនៅស្រុកខ្មែរគេរែកលក់តាមផ្ទះ។ ប៉ុណ្ណារូចូលចិត្តហូបនុំប៉ាវ សាច់សម៉ដ្ឋខៃ ទិញមកពីផ្សារបាយឆៅនោះណាស់ តែយើងសង្កេតឃើញថា ទោះជាយើងហូបបន្លែច្រើនក៏ដោយមិនដូចបន្លែនៅស្រុកខ្មែរទេ **តទៅលេខក្រោយ**


# CLASSIFIED ADS

**CALL:** **978.677.7163**

EMAIL: SOBENPIN@KHMERPOST.US

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

**$50** ក្នុង១ខែ

***CALL:***
***978.677.7163***

*EMAIL:* *SOBENPIN@KHMERPOST.US*

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.

## ជាវសៀវភៅតាមកាសែតខ្មែរផុសស.រ.អា



រឿងរាមកេរ្តិ៍ ដោយសាគុ សាមុត តម្លៃ $10



របាំបុរាណខ្មែរ ដោយសាគុ សាមុត តម្លៃ $10



រឿងរាមកេរ្តិ៍ ដោយសាគុ សាមុត តម្លៃ $10



ក្រុងភ្នំពេញមុនឆ្នាំ១៩៨៤ តម្លៃ $10



CAMBODGE តម្លៃ $5


អង្គការជានរណា? បីភាគ តម្លៃ $5/1

សូមកាត់ត្រង់នេះផ្ញើមកយើង

| | |
|---|---|
| អាស័យដ្ឋានយើង៖ 45 Merrimack St., Suite 218A, Lowell, MA 01852 | ឈ្មោះសៀវភៅដែលទិញ តម្លៃ$...... |
| ឈ្មោះ និងអាស័យដ្ឋានរបស់លោកអ្នក | តម្លៃ$...... |
| អាស័យដ្ឋាន | ចំនួនសៀវភៅសរុប៖ |
| ក្រុង, រដ្ឋ, លេខប្រៃសណីយ៍ | ថ្លៃសៀវភៅសរុប តម្លៃសរុប$...... |
| ទូរស័ព្ទ/ អ៊ីម៉ែល: | សូមផ្ញើជា Check ឬ Money order ទៅ KhmerPostUSA នៅអាស័យដ្ឋានខាងលើ |

# រមណីយដ្ឋានទឹកឆានៅខេត្តកំពង់ចាម ជាតំបន់ទេសចរណ៍ដ៏ទាក់ទាញ



**កំពង់ចាម** : រមណីយដ្ឋានទឹកឆាស្ថិតនៅភូមិថ្មី ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលមានចម្ងាយប្រមាណ៤២គីឡូម៉ែត្រ ពីក្រុងកំពង់ចាម។ ភ្ញៀវទេសចរណ៍អាចធ្វើដំណើរទៅប្រាសាទព្រះធាតុទឹកឆាពីក្រុងកំពង់ចាមឆ្ពោះទៅស្រុកព្រៃឈរដល់ផ្សារព្រៃទទឹងបត់ទៅស្ដាំតាមផ្លូវចម្ងាយ១៤គីឡូម៉ែត្រទៅដល់ស្ពានអ្នកតាស្ទឹង រួចបត់ទៅស្ដាំតាមបណ្ដោយប្រឡាយទឹកមួយមានប្រភពពីទឹកឆា បន្ទាប់មកធ្វើដំណើរប្រមាណ៤គីឡូម៉ែត្រទៀតទើបទៅដល់។ ភ្ញៀវទេសចរណ៍អាចរីករាយក្នុងការលេងទឹកដែលមានប្រភពមកពីទឹកផុសក្នុងដី ហើយវាជាភាពទាក់ទាញយ៉ាងសំខាន់សម្រាប់តំបន់មួយនេះ ដែលគេហៅថា ក្បាលទឹក។

លោក ស៊ាន សុគុណ ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាមបានបញ្ជាក់ឱ្យដឹងពីទីតាំងភូមិសាស្ត្រថា តំបន់ទឹកឆានេះ ខាងជើងគឺជាខ្ពង់រាបមានកូនភ្នំមួយចំនួននៅជាប់មាត់ទឹក។ នៅជុំវិញតំបន់នេះ មានព្រែកធំៗជាច្រើនហូរចាក់ដូចជាព្រែកកំពង់សាជាដើម។ ផ្នែកខាងត្បូង គឺជាទំនាបដែលជាជំរាលពីខ្ពង់រាបផ្នែកខាងជើងទំនាបនេះគឺជាផ្ទៃបឹងទឹកឆាដែលជាបឹងធម្មជាតិមួយដ៏ធំស្ថិតនៅខាងជើងនៃស្រុកព្រៃឈរ និងជាទីរមណីយដ្ឋានដែលគួរជាទីពេញចិត្តដល់អ្នកដែលចូលចិត្តធម្មជាតិ។ ទីនេះមានចរន្តទឹកហូរខ្លាំងមានប្រភពមកពីកន្លែងមួយឈ្មោះថា ក្បាលទឹក ដែលមានចម្ងាយ២គីឡូម៉ែត្រ នៅខាងលិចភ្នំធាតុ។ ទីនោះជាចំណុចខ្ពស់បំផុតនៃខ្ពង់រាបរបស់តំបន់ដែលមានប្រភពទឹកជាច្រើនហូរចេញពីក្នុងដីនៅកន្លែងមានដើមឈើធំៗ។ បរិវេណក្បាលទឹកនេះ មានមាត្រដ្ឋានប្រមាណជា២០០ទៅ៣០០ម៉ែត្រ។ ក្បាលទឹកមួយស្ថិតនៅភាគខាងត្បូងនៅក្នុងបរិវេណនៃក្បាលទឹកនេះ មានទឹកផុសចេញគ្រប់ពេល ហើយហូរបែកចេញតាមកូនអូរតូចៗដែលនៅជុំវិញនោះ។ ទីប្រជុំក្បាលទឹកទាំង៣នៅជិតគ្នាបង្កើតបានជាប្រភពទឹកមួយហូរចេញដែលមានជម្រៅកន្លះម៉ែត្រ។ ចរន្តទឹកហូរស្ទើរតែទោះជានៅរដូវប្រាំង ឬវស្សាក៏ដោយលើកលែងតែពេលភ្លៀងខ្លាំង និងទឹកជំនន់ម្ដងម្កាលដែលធ្វើឱ្យចរន្តទឹកហូរខ្លាំងខុសធម្មតា។ ខ្សែទឹកដែលហូរចេញមកនេះមានទំហំពី៨ទៅ១០ម៉ែត្រ បន្ទាប់មកហូរធ្លាក់សំដៅទៅទិសខាងលិចបញ្ចេញជាស្នូរ។ ពេលទឹកហូរមកដល់ទំនាបកណ្ដាលដែលមានទ្វារទឹក២ធំៗសង់នៅសម័យសង្គមរាស្ត្រនិយម។ ទឹកបានហូរធ្លាក់ទៅផ្ទៃបឹងខាងលិចធ្វើឱ្យមានស្នូរ។ ទ្វារទឹកទីមួយសាងសង់វារីអគ្គិសនីខ្នាតតូចរួមជាមួយថាមពលពន្លឺព្រះអាទិត្យមានកម្លាំង១១០គីឡូវ៉ាត់ម៉ោង ជាអំណោយរបស់រាជរដ្ឋាភិបាលជប៉ុន។ តំបន់នេះមានបន្សល់នូវសំណល់ប្រាសាទបុរាណជាច្រើន។ ប្រាសាទដែលសំខាន់ជាងគេ គឺបោសព្រះនន់ និងគុកតូច បោសព្រះនន់ ឬគុកធំ ឬប្រាសាទស្រី និងគុកតូច ឬប្រាសាទប្រុស។

លោកប្រធានមន្ទីរបានបញ្ជាក់ឱ្យដឹងទៀតថា ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ខេត្តកំពង់ចាមបានទទួលភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាកំសាន្តចំនួន២៣៥០០០នាក់ កើនឡើងជាងឆ្នាំ២០១៣។ រមណីយដ្ឋានធម្មជាតិទឹកឆា ក៏ជាសក្ដានុពលដ៏ទាក់ទាញយ៉ាងសំខាន់សម្រាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិអាចមកស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរពីបុរាណកាល។ ម្យ៉ាងទៀតដោយសារខេត្តមានសន្តិសុខល្អក្រោមការយកចិត្តទុកដាក់ការពារផ្ដល់នូវសុវត្ថិភាពពីអាជ្ញាធរខេត្តសមត្ថកិច្ចមូលដ្ឋាន និងសមត្ថកិច្ចនគរបាលទេសចរណ៍ប្រចាំការបានល្អក្នុងតំបន់នេះផងដែរ៕


LOWELL ELDER CARE 978-596-1111

## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយ ដែលផ្ដល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្ដល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្ដៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

សូមហៅលេខទូរស័ព្ទ (978) 596-1111

City of Lights Parade

# ដង្ហែក្បួនឆ្នាំ២០១៤ នៅឡូវែលក្រុងដែលពោរពេញដោយពន្លឺ

## 2014 City of Lights Parade & Holiday Celebration

**Saturday, November 29 | 12pm – 8pm ថ្ងៃសៅរ៍ ទី២៩ វិច្ឆិកា ឆ្នាំ២០១៤**
**Visit Lowell.org for details!**
**Parade Start Time is 4:30pm ចាប់ផ្តើមនៅម៉ោង៤:៣០នាទីរសៀល**
**Event Information Center is at 103 Market Street**

## កម្រងរូបថតអនុស្សាវរីយ៍




















# KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

## 978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

## Reserve Your 2014 Ads with us today and receive up to 20% OFF!

(Please mention this coupon ad: Summer 2014)

## Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ Page Size | ប្រវែង Length x Width | 1ខែ 1 month 10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/4 Classify Ad | (6.5"x5") | $160 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

## Our 2014 Publishing Dates កាលវិភាគបោះពុម្ព

November 7th & 21st
December 5th & 19th

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852
Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092
Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com
www.khmerpost.us | www.facebook.com/KhmerPostUSA